ក្រសួងកិច្ចការនារី
MINISTRY OF WOMEN'S AFFAIRS

# គោលការណ៍ណែនាំ

## ស្តីពី

## ការបញ្ជូនស្ត្រី និងក្មេងស្រី ដែលជាជនរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ

ឆ្នាំ ២០១៦


រៀបចំឡើង ដោយមានការគាំទ្រពីៈ

Australian Aid

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

អនុវត្តដោយៈ

giz Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) GmbH

# មាតិកា


**អារម្ភកថា** ..... **៣**

**អក្សរកាត់** ..... **៥**

**និយមន័យនៃពាក្យគន្លឹះ** ..... **៧**

**ផ្នែកទី ១ សេចក្តីផ្តើម** ..... **១១**

១.១ ប្រវត្តិ ..... ១១

១.២ វិសាលភាពនៃគោលការណ៍ណែនាំ ..... ១៣

១.៣ ចំណុចខ្វះខាតនៃគោលការណ៍ណែនាំ ..... ១៣

**ផ្នែកទី ២ គោលការណ៍ណែនាំសម្រាប់អ្នកផ្តល់សេវា នៅពេលបញ្ជូន និងទទួលជនរងគ្រោះ** ..... **១៤**

**ផ្នែកទី ៣ បទដ្ឋានអប្បបរមា និងគោលការណ៍ណែនាំដែលពាក់ព័ន្ធនានា នៅប្រទេសកម្ពុជា** ..... **១៦**

**ផ្នែកទី ៤ តួនាទី និងការទទួលខុសត្រូវសម្រាប់ការបញ្ជូនជនរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកូនរបស់ពួកគេ** ..... **១៧**

៤.១ តួនាទីរបស់ស្ថាប័នសម្របសម្រួល ..... ១៧

៤.២ ជំនាញរបស់អ្នកផ្តល់សេវា និងការបញ្ជូនដោយផ្អែកលើការវាយតម្លៃអំពីតម្រូវការ ..... ១៨

៤.៣ ការសម្របសម្រួលបញ្ជូនជនរងគ្រោះនៅក្នុងរង្វង់ស្ថាប័នតែមួយ ..... ១៩

៤.៤ ការសម្របសម្រួលបញ្ជូនរវាងអន្តរស្ថាប័នដោយប្រើទម្រង់
ចុះបញ្ជីករណី និងទម្រង់បញ្ជូន ........ ២០
៤.៥ ការចាត់តាំងជនបង្គោលតាមស្ថាប័នទទួល ........ ២១
៤.៦ ការធ្វើអន្តរាគមន៍ពេលមានវិបត្តិ និងការបញ្ជូនទៅរក
សេវាថែទាំសុខភាព ........ ២២
៤.៧ ការផ្តល់សុវត្ថិភាពជាបន្ទាន់សម្រាប់ជនរងគ្រោះ និងកូន
របស់ពួកគេ ព្រមទាំងអ្នកផ្តល់សេវា ........ ២៣
៤.៨ ការណែនាំ និងការគ្រប់គ្រងក្រុមសហគមន៍ និងអ្នកស្ម័គ្រចិត្ត ........ ២៤
៤.៩ ការតាមដានបន្តបន្ទាប់ពីការបញ្ជូន ........ ២៤
៤.១០ ការផ្តល់សេវាត្រូវផ្អែកទៅលើប្រភេទផ្សេងៗនៃអំពើហិង្សា
ទាក់ទងនឹងយេនឌ័រ ........ ២៥
**ឧបសម្ព័ន្ធ ១ - ទម្រង់ចុះបញ្ជីករណី ........ ២៦**
**ឧបសម្ព័ន្ធ ២ - ទម្រង់បញ្ជូនជនរងគ្រោះ ........ ៣៤**
**ឧបសម្ព័ន្ធ ៣ - ទម្រង់ផ្តល់យោបល់ត្រឡប់ស្តីពីការបញ្ជូន ........ ៣៦**
**ឧបសម្ព័ន្ធ ៤ - សេចក្តីសង្ខេបនៃទម្រង់បញ្ជូនករណី ........ ៣៨**
**ឧបសម្ព័ន្ធ ៥ - ដំណើរការគ្រប់គ្រងករណី ........ ៣៩**

# អារម្ភកថា

សៀវភៅ "គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រី និងក្មេងស្រី ដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (ក្រសួងកិច្ចការនារីឆ្នាំ២០១៦)" នឹងយកទៅប្រើប្រាស់ដោយភ្នាក់ងារផ្តល់សេវាពាក់ព័ន្ធនានា រួមទាំងភ្នាក់ងារនគរបាលយុត្តិធម៌នៃក្រសួងកិច្ចការនារី ដើម្បីបង្កើនគុណភាពសេវាកម្មដល់ស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

សៀវភៅគោលការណ៍ណែនាំនេះ រៀបរៀងឡើងដើម្បីឆ្លើយតបទៅនឹងយុទ្ធសាស្ត្រទី២ "ការការពារផ្នែកច្បាប់ និងសេវាកម្ម" នៃផែនការសកម្មភាពជាតិ ស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ឆ្នាំ២០១៤-២០១៨ និងស្របតាមផែនការយុទ្ធសាស្ត្រដើម្បីសមភាពយេនឌ័រ និងការបង្កើនភាពអង់អាចដល់ស្ត្រី នៃផែនការយុទ្ធសាស្ត្រនារីរតនៈទី៤ របស់ក្រសួងកិច្ចការនារី ដែលរៀបចំឡើងដើម្បីធានាដល់ស្ត្រីនិងក្មេងស្រី ក្នុងការទទួលបាននូវកិច្ចការពារផ្លូវច្បាប់ដោយស្មើភាព។ គោលការណ៍ណែនាំនេះ ជាការបំពេញបន្ថែមទៅលើច្បាប់ដែលមានស្រាប់នៅកម្ពុជា ដើម្បីបញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រី ជាពិសេសច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ ឆ្នាំ២០០៥ និងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧។

ការរៀបចំគោលការណ៍ណែនាំនេះ បានបង្ហាញអំពីការខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការអនុវត្តន៍នូវគោលនយោបាយជាតិនិងច្បាប់នានាឱ្យមានភាពស៊ីសង្វាក់គ្នាទៅនឹងអនុសញ្ញាអន្តរជាតិស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ (CEDAW) និងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិមនុស្សផងដែរ។

ខ្ញុំមានជំនឿយ៉ាងមុតមាំថា សៀវភៅគោលការណ៍ណែនាំនេះ នឹងក្លាយជាឧបករណ៍ដ៏មានសារៈប្រយោជន៍ សម្រាប់ជួយពង្រឹងកិច្ចសហការយ៉ាងមុតមាំ រវាងក្រសួងស្ថាប័នពាក់ព័ន្ធ អង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដោយធានាការបញ្ជូនស្ត្រី និងក្មេងស្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រឱ្យបានទាន់ពេលវេលា និងមានប្រសិទ្ធភាព ដែលជាផ្នែកមួយដ៏សំខាន់នៃការទទួលខុសត្រូវដើម្បីកាត់បន្ថយអំពើហិង្សាលើស្ត្រី និងក្មេងស្រី។

តាងនាមក្រសួងកិច្ចការនារី ខ្ញុំសូមថ្លែងអំណរគុណដល់ក្រសួងស្ថាប័ន និងអង្គការក្រៅរដ្ឋាភិបាលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលពាក់ព័ន្ធ ព្រមទាំងអ្នកជំនាញការជាតិ និងអន្តរជាតិ ចំពោះកិច្ចសហការដ៏ល្អ និងបានចូលរួមផ្តល់យោបល់លើដំណើរការតាក់តែង

គោលការណ៍ណែនាំនេះ។ ខ្ញុំសូមថ្លែងអំណរគុណផងដែរ ដល់ដៃគូអភិវឌ្ឍន៍ ចំពោះកិច្ចគាំទ្រទាំងបច្ចេកទេស និងហិរញ្ញវត្ថុ ក្នុងនោះមានអ្នកជំនាញការបច្ចេកទេស ដែលផ្តល់ដោយគម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រី ដំណាក់កាលទី២ គាំទ្រដោយអង្គការជីអាយហ្សិត(GIZ) ដើម្បីបង្កើតគោលការណ៍ណែនាំនេះ ជាពិសេស ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ច (BMZ) ក្រសួងការបរទេសនិងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី (DFAT) និងអង្គការ GIZ ដែលជាដៃគូទ្វេភាគីជាមួយក្រសួងកិច្ចការនារី ក្នុងការអនុវត្តន៍គម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រី ដំណាក់កាលទី២ ឆ្នាំ២០១៤-២០១៦ នេះ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**វេជ្ជ. អ៊ឹង កន្ថាផាវី**

# អក្សរកាត់

| | |
|---|---|
| Spanish Agency for International Development Cooperation (AECID) | ស្ថាប័នអេស្ប៉ាញសម្រាប់សហប្រតិបត្តិការអន្តរជាតិនិងការអភិវឌ្ឍន៍ |
| Access to Justice for Women (ATJW I) | គម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រី ដំណាក់កាលទី១ |
| Access to Justice for Women (ATJW II) | គម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រី ដំណាក់កាលទី២ |
| The German Federal Ministry for Economic Development and Cooperation (BMZ) | ក្រសួងសហប្រតិបត្តិការ និងអភិវឌ្ឍន៍សេដ្ឋកិច្ចអាល្លឺម៉ង់ |
| Client Center Approach (CCA) | គោលការណ៍ផ្តោតលើអតិថិជនជាចម្បង |
| Convention on the Elimination of All Forms of Discrimination against Women (CEDAW) | អនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងនារីភេទ |
| Australian Department of Foreign Affair and Trade (DFAT) | ក្រសួងការបរទេស និងពាណិជ្ជកម្មនៃប្រទេសអូស្ត្រាលី |
| Gender-based Violence (GBV) | អំពើហិង្សាទាក់ទងនឹងយេនឌ័រ |
| GIZ Deutsche Gesellschaft für Internationale Zusammernarbeit | អង្គការជីអាយហ្សិត |
| Ministry of Health (MoH) | ក្រសួងសុខាភិបាល |
| Ministry of Social Affairs Veteran and Youth (MoSAVY) | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា |

| | |
|---|---|
| Ministry of Women Affairs (MoWA) | ក្រសួងកិច្ចការនារី |
| National Action Plans to Prevent Violence Against Women ( NAPVAW) 2014-2018 | ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រី ២០១៤-២០១៨ |
| Provincial Department of Women's Affairs (PDoWA) | មន្ទីរកិច្ចការនារីខេត្ត |
| Referral Guidelines for Women and Girl Survivors of Gender based Violence Against Women (Referral Guidelines) | គោលការណ៍ណែនាំស្តីពីការបញ្ជូនស្ត្រីនិងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ (គោលការណ៍ណែនាំស្តីពីការបញ្ជូន) |
| United Nation Population Fund (UNFPA) | មូលនិធិប្រជាជននៃអង្គការសហប្រជាជាតិ |
| STIs | ការឆ្លងជម្ងឺកាមរោគ |
| World Health Organization (WHO) | អង្គការសុខភាពពិភពលោក |
| Women and Children Consultative Committees (WCCCs) | គណៈកម្មការពិគ្រោះយោបល់កិច្ចការស្ត្រីនិងកុមារ (គ.ក.ស.ក) |

# និយមន័យនៃពាក្យគន្លឹះ[1]

**ការប្រឹក្សាយោបល់ជាមូលដ្ឋាន** ៖ វិធីសាស្រ្ត ដែលអ្នកផ្តល់សេវាធ្វើទំនាក់ទំនងជាមួយជនរងគ្រោះ ព្រមទាំងផ្តល់នូវសេវាថែទាំផ្នែកផ្លូវចិត្ត និងតាមតម្រូវការជាក់ស្តែងជាបន្ទាន់។

**ការគ្រប់គ្រងករណី** ៖ វិធីសាស្រ្តនៃការផ្តល់សេវាដោយផ្អែកលើការវាយតម្លៃអំពីតម្រូវការ ការសម្របសម្រួលសេវាចម្រុះដែលផ្តល់ដោយអ្នកផ្តល់សេវាផ្សេងៗដើម្បីឆ្លើយតបចំពោះតម្រូវការរបស់ជនរងគ្រោះ[2]។

**អ្នកគ្រប់គ្រងករណី** ៖ បុគ្គលិកដែលធ្វើការសម្របសម្រួលដំណើរការនៃការគ្រប់គ្រងករណី រួមទាំង ការវាយតម្លៃអំពីតម្រូវការ និងការសម្របសម្រួលសេវា ការបញ្ជូនជនរងគ្រោះទៅអ្នកផ្តល់សេវាផ្សេងៗ ការតាមដានករណី និងការបិទករណី។ អ្នកគ្រប់គ្រងករណីក៏ទទួលខុសត្រូវផងដែរចំពោះការរៀបចំឯកសារអំពី សេវាទាំងអស់ ដែលបានផ្តល់ដល់ជនរងគ្រោះ ឬសេវាបញ្ជូនជនរងគ្រោះ។

**កុមារ** ៖ សំដៅលើជនទាំងឡាយដែលមានអាយុក្រោម ១៨ ឆ្នាំ ស្របតាមច្បាប់ដែលមានចែងពីកុមារ ដែលភាគច្រើន គួរត្រូវបានកំណត់ជាមុន។

**ការបង្ខិតបង្ខំ** ៖ ការបង្ខំ ឬប៉ុនប៉ងបង្ខំជនម្នាក់ទៀតឱ្យប្រព្រឹត្តអាកប្បកិរិយាអ្វីមួយផ្ទុយពីឆន្ទៈរបស់ពួកគេ ដោយប្រើប្រាស់នូវការគំរាមកំហែង ការជម្រុញដោយពាក្យសំដី ឧបាយកលបោកបញ្ឆោត ការបំភាន់ ឬប្រើប្រាស់ការអូសទាញ តាមរយៈវប្បធម៌ ឬប្រើប្រាស់អំណាចផ្នែកសេដ្ឋកិច្ច។

**សហគមន៍អ្នកអនុវត្ត** ៖ សហគមន៍អ្នកអនុវត្ត គឺជាក្រុមមនុស្សមួយក្រុមដែលចែករំលែកនូវកង្វល់ រួម បញ្ហាមួយចំនួន ឬការយល់ឃើញតាមរយៈប្រធានបទមួយ ហើយពួកគេជួបជុំគ្នាចែករំលែកនូវការអនុវត្តល្អៗ លើកស្ទួយនូវទំនាក់ទំនងសហប្រតិបត្តិការ និងបង្កើតនូវចំណេះដឹងថ្មីៗ ដើម្បីចែករំលែកជាមួយគ្នាទៅតាមជំនាញ និងវិស័យរបស់ពួកគេ[3]។

---

1 និយមន័យកំណត់នៅក្នុងគោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់គ្រប់គ្រងអំពើហិង្សាលើស្រ្តីនៅក្នុងប្រព័ន្ធសុខាភិបាល សៀវភៅគ្លីនិករបស់អង្គការសុខភាពពិភពលោកអំពីស្រ្តីរងគ្រោះពីអំពើហិង្សាដោយដៃគូស្និទ្ធស្នាល និងអំពើហិង្សាផ្លូវភេទនៅក្នុងប្រទេសកម្ពុជា និងបទដ្ឋានអប្បបរមាស្តីពីការប្រឹក្សាយោបល់ជាមូលដ្ឋានសម្រាប់ស្រ្តីរងគ្រោះពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ លើកលែងតែមានចែង។

2 សមាគមជាតិនៃបុគ្គលិកសង្គមកិច្ច។ សូមមើល http://work.chron.com/social-work-case-manager-9271.html

3 GIZ. ឧបករណ៍ស្តីពីកត្តាជោគជ័យនៃការកសាងសមត្ថភាព និងគោលការណ៍ណែនាំសម្រាប់សហគមន៍អ្នកអនុវត្ត អាចមើល https://net.educause.edu/ir/library/pdf/nli0531.pdf.

**ការយល់ព្រម** ៖ ការជ្រើសរើសធ្វើអ្វីមួយដោយសេរី និងដោយការស្ម័គ្រចិត្តបន្ទាប់ពីបានទទួលនូវព័ត៌មានពេញលេញ។ ការយល់ព្រម នឹងមិនយកជាការនោះទេ ប្រសិនបើ ការព្រមព្រៀងនោះធ្វើឡើងតាមរយៈការប្រើប្រាស់ ការគំរាមកំហែង ការបង្ខិតបង្ខំ ឬទម្រង់ផ្សេងទៀតនៃការបង្ខិតបង្ខំ ការចាប់ពង្រត់ ការបោកបញ្ឆោត ការបំភាន់ ឬការធ្វើឱ្យយល់ខុស។

**អំពើហិង្សាក្នុងគ្រួសារ** ៖ អំពើហិង្សាក្នុងគ្រួសារ ដូចបានកំណត់ក្នុងនិយមន័យនៃច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ(ឆ្នាំ ២០០៥) ដែលរួមបញ្ចូលអំពើហិង្សាលើប្តី ឬប្រពន្ធ កូនក្នុងបន្ទុក ឬបុគ្គលដែលរស់នៅក្រោមដំបូលផ្ទះតែមួយ និងអ្នកដែលពឹងពាក់ស្នាក់អាស្រ័យជាមួយគ្រួសារនោះ។

**អ្នកអនុវត្តភារកិច្ច** ៖ អ្នកអនុវត្តភារកិច្ច គឺជាតួអង្គទាំងឡាយដែលមានកាតព្វកិច្ចជាក់លាក់ ឬការទទួលខុសត្រូវក្នុងការគោរព ការលើកកម្ពស់សិទ្ធិមនុស្ស និងមិនរំលោភសិទ្ធិមនុស្ស។ ពាក្យនេះ ជារួមប្រើសំដៅលើតួអង្គរដ្ឋ ក៏ប៉ុន្តែ តួអង្គមិនមែនរដ្ឋ ក៏អាចចាត់ទុកថាជាអ្នកអនុវត្តភារកិច្ចផងដែរ។ អ្នកពាក់ព័ន្ធផ្សេងទៀត (ឧទាហរណ៍ ឪពុកម្តាយ) អង្គការក្នុងស្រុក ក្រុមហ៊ុនឯកជនម្ចាស់ជំនួយ និង ស្ថាប័នអន្តរជាតិ ក៏ជាអ្នកអនុវត្តភារកិច្ចផងដែរ។

**អំពើហិង្សាទាក់ទងនឹងយេនឌ័រ** ៖ នៅក្នុងឯកសារនេះ អំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានកំណត់ថា "ជាអំពើហិង្សាដែលបង្កមកលើនារីភេទ ឬដែលបង្កផលប៉ះពាល់មកលើស្ត្រីដោយចំពោះ រួមមាន អំពើដែលបង្ករបួសស្នាមដល់រាងកាយ ផ្លូវចិត្ត ផ្លូវអារម្មណ៍ ឬផ្លូវភេទ ឬអំពើបង្កការឈឺចាប់ ទទួលរងនូវការគំរាមកំហែង ការបង្ខិតបង្ខំ និងការដកហូតសិទ្ធិសេរីភាពដទៃទៀត"។

**អំពើប្រទូស្តកេរខ្មាស** ៖ មាត្រា ២៤៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ ២០១០ កំណត់និយមន័យអំពើប្រទូស្តកេរខ្មាសថាគ្រប់អំពើប៉ះពាល់ ស្ទាបអង្អែលកេរភេទ ឬផ្នែកភេទផ្សេងទៀតរបស់បុគ្គលដទៃ តែបុគ្គលនេះមិនស្ម័គ្រផងទេ ឬបង្ខំបុគ្គលដទៃឱ្យប្រព្រឹត្តអំពើនេះមកលើខ្លួន ឬទៅលើតតិយបុគ្គលក្នុងគោលបំណងធ្វើឱ្យរំជួល ឬរីករាយដល់ចំណង់ផ្លូវភេទរបស់ជនល្មើស។

**អំពើបង្ហាញកេរភេទ** ៖ មាត្រា ២៤៩ នៃក្រមព្រហ្មទណ្ឌកម្ពុជាកំណត់និយមន័យនៃអំពើបង្ហាញកេរភេទថាជាអំពើ បង្ហាញកេរភេទដែលនាំឱ្យអ្នកដទៃមើលឃើញនៅក្នុងទីកន្លែងមួយដែលសាធារណជនអាចមើលឃើញ។

**អំពើហិង្សាដោយដៃគូ ស្និទ្ធស្នាល** ៖ អាកប្បកិរិយាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល ឬអតីតដៃគូ ដែលបណ្តាលឱ្យមានរបួសស្នាមលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ក្នុងនោះមានអំពើឈ្លានពាន លើរាងកាយ ការបង្ខិតបង្ខំរួមភេទ និងការធ្វើបាបផ្លូវចិត្ត និងអាកប្បកិរិយា គ្រប់គ្រង។

**ស្ថាប័ន** ៖ សំដៅលើទីភ្នាក់ងារផ្តល់សេវានានា ដែលបំពេញការងារក្នុងរដ្ឋាភិបាល ឬមិនមែន រដ្ឋាភិបាល

**ជនមុខសញ្ញា** ៖ បុគ្គលម្នាក់ ក្រុម ឬស្ថាប័នមួយដែលបង្កអំពើហិង្សា គាំទ្រ និងអត់ឱនដោយ ផ្ទាល់ ឬដោយប្រយោលចំពោះអំពើហិង្សា ឬការរំលោភបំពានផ្សេងទៀតមកលើ បុគ្គលម្នាក់ ឬ បុគ្គលមួយក្រុម។

**រំលោភសេពសន្ថវៈ** ៖ មាត្រា ២៣៩ នៃក្រមព្រហ្មទណ្ឌកម្ពុជា ផ្តល់និយមន័យពាក្យរំលោភ សេពសន្ថវៈថាជា គ្រប់អំពើបញ្ចូលអង្គជាត តាមបែបណាក៏ដោយ ឬអំពើបញ្ចូល ឧបករណ៍ណា មួយទៅក្នុងអង្គជាត ដែលប្រព្រឹត្តទៅលើអ្នកដទៃទោះបីមាន ភេទដូចគ្នា ឬមិនដូចគ្នា ក៏ដោយ ការប្រើហិង្សា ការបង្ខិតបង្ខំ ការគំរាមកំហែង ឬដោយការឆ្លៀតឱកាស[6]។

**ការបញ្ជូនជនរងគ្រោះ** ៖ គឺជាដំណើរការនៃការបញ្ជូនជនរងគ្រោះទៅរកសេវាដ៏សមស្រប។ ការបញ្ជូនអាចធ្វើឡើងជា ៣កម្រិត រួមមាន៖

១) ***ការទៅរកសេវាដោយជនរងគ្រោះខ្លួនឯង៖*** សកម្មភាពនេះកើតមានឡើង នៅ ពេលដែលជនរងគ្រោះ ធ្វើទំនាក់ទំនងដោយផ្ទាល់ជាមួយអ្នកផ្តល់សេវា ហើយគាត់មិនត្រូវ បានបញ្ជូនឬអន្តរាគមន៍ដោយបុគ្គលណាផ្សេងឡើយ។

២) ***ការបញ្ជូនដោយអន្តរស្ថាប័ន៖*** ជាការបញ្ជូនជនរងគ្រោះពីស្ថាប័នមួយទៅស្ថាប័ន មួយទៀត ឧទាហរណ៍ ការបញ្ជូនជនរងគ្រោះពីស្ថាប័នជំនួយផ្លូវច្បាប់ទៅស្ថាប័នដែលមាន មណ្ឌលស្នាក់នៅ ឬការបញ្ជូនជនរងគ្រោះពីស្ថាប័នរដ្ឋ ទៅអង្គការមិនមែនរដ្ឋាភិបាលនានា។

៣) ***ការបញ្ជូនផ្ទៃក្នុងស្ថាប័ន៖*** ជាការបញ្ជូនជនរងគ្រោះឱ្យទទួលបានសេវាផ្សេងៗនៅ ក្នុងស្ថាប័នតែមួយ។ ការបញ្ជូនបែបនេះ អាចមានទម្រង់ច្រើនប្រភេទ ឧទាហរណ៍ ការបញ្ជូន ពីអ្នកស្ម័គ្រចិត្តដែលធ្វើការនៅថ្នាក់សហគមន៍ ទៅកាន់ការិយាល័យរបស់ភ្នាក់ងារផ្តល់សេវា នៅក្នុងខេត្ត/ក្រុង ឬវាជាការបញ្ជូនជនរងគ្រោះពីផ្នែកផ្សេងគ្នានៃស្ថាបន័/អង្គការតែមួយ ដូចជា ការបញ្ជូនពីបុគ្គលដែលទទួលជនរងគ្រោះដំបូងគេ ទៅរកអ្នកពិគ្រោះយោបល់ជាដើម។

**អ្នកផ្តល់សេវា** ៖ រាល់បុគ្គលិកនៃស្ថាប័ន ដែលជារបស់រដ្ឋ និងមិនមែនរដ្ឋ អ្នកស្ម័គ្រចិត្តនិងអ្នកអនុវត្តភារកិច្ចទាំងអស់ ដែលផ្តល់សេវា និងការជួយគាំទ្រដល់ជនរងគ្រោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ។

**អំពើរុកកួនខាងផ្លូវភេទ** ៖ មាត្រា ២៥០ នៃក្រមព្រហ្មទណ្ឌកម្ពុជាកំណត់និយមន័យនៃពាក្យរុកកួនផ្លូវភេទថាជាអំពើដែលបុគ្គលម្នាក់រំលោភអំណាចដោយយកមុខងាររបស់ខ្លួនប្រគល់ឱ្យធ្វើការគាបសង្កត់ម្តងហើយម្តងទៀតទៅលើអ្នកដទៃ ក្នុងគោលបំណងទទួលការអនុគ្រោះខាងផ្លូវភេទ។

**អំពើហិង្សាផ្លូវភេទ** ៖ សកម្មភាពផ្លូវភេទណាមួយ ការប៉ុនប៉ងដើម្បីទទួលបានការរួមភេទ ការប្រើពាក្យសំដីលេងសើច ឬការព្យាយាម ឬធ្វើសកម្មភាពដើម្បីធ្វើការជួញដូរ ឬ ដើម្បីបម្រើផ្លូវភេទរបស់បុគ្គលនោះ តាមរយៈការបង្ខិតបង្ខំពីជននោះ ដោយមិនគិតពីទំនាក់ទំនងរបស់ពួកគេជាមួយជនរងគ្រោះ នៅក្នុងទីកន្លែងណាក៏ដោយ មានជាអាទិ៍ នៅក្នុងផ្ទះ និងកន្លែងធ្វើការ។

**ជនរងគ្រោះ** ៖ ជនដែលត្រូវបានគេរំលោភលើរាងកាយ ផ្លូវភេទ និង/ឬផ្លូវចិត្ត ហើយកំពុងទទួលសេវាពីអ្នកផ្តល់សេវា។ អ្នកផ្តល់សេវាខ្លះហៅជនរងគ្រោះថាជា អតិថិជន អ្នកជម្ងឺ ជនរងគ្រោះពីបទល្មើស ឬងារផ្សេងទៀត។

**អំពើហិង្សាលើស្ត្រី** ៖ អំពើណាមួយនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលបណ្តាលឱ្យ ឬអាចបណ្តាលឱ្យមានរបួសស្នាមលើរាងកាយ ផ្លូវភេទ ឬផ្លូវចិត្ត ឬការឈឺចាប់ដល់ស្ត្រី រួមមានការគំរាមកំហែងដោយអំពើនោះ ការបង្ខិតបង្ខំ ឬការដកហូតនូវសេរីភាពតាមទំនើងចិត្ត ទោះអំពើនេះកើតឡើងនៅក្នុងជីវិតជាសាធារណៈ ឬនៅក្នុងជីវិតជាឯកជនក៏ដោយ។

# ផ្នែកទី ១ សេចក្តីផ្តើម

## ១.១ ប្រវត្តិ

***គោលការណ៍ណែនាំស្តីពីការបញ្ជូនជនរងគ្រោះជាស្ត្រី និងកុមារី ដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ(គោលការណ៍ណែនាំ)***នេះ ត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់ការផ្តល់សេវាឱ្យបានគ្រប់ជ្រុងជ្រោយដល់ស្ត្រី និងក្មេងស្រីដែលជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ តាមរយៈប្រព័ន្ធ ចុះបញ្ជីករណី ការវាយតម្លៃអំពីតម្រូវការរបស់ជនរងគ្រោះ និងការបញ្ជូនជនរងគ្រោះទៅរកសេវាដទៃទៀតដោយផ្អែកលើតម្រូវការជាបុគ្គល និងការព្រមព្រៀងពីជនរងគ្រោះ។

អំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺជាអំពើហិង្សាប្រឆាំងនឹងសិទ្ធិមនុស្ស ដែលជាប់ទាក់ទងទៅនឹងជីវិតរស់នៅរបស់ស្ត្រី។ យោងតាមការសិក្សារបស់អង្គការទស្សនពិភពលោកស្ត្រី ១នាក់ក្នុងចំណោម ៣នាក់ ក្នុងពិភពលោកទទួលរងបទពិសោធន៍ហិង្សាផ្លូវកាយ និងហិង្សាផ្លូវភេទដោយដៃគូរបស់ពួកគេ ឬទទួលរងហិង្សាផ្លូវភេទដោយអ្នកដែលមិនមែនជាដៃគូ[4] ការសិក្សាស្រាវជ្រាវមុនៗបានបង្ហាញថា ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅក្នុងប្រទេសកម្ពុជា មានតម្រូវការចម្រុះ និងស្មុគស្មាញ ហើយសេវាឆ្លើយតបស្ថិតនៅបែកខ្ញែកគ្នា និងមិនទាន់មានការសម្របសម្រួលឱ្យបានគ្រប់ជ្រុងជ្រោយនៅឡើយ[5]។ ផែនការសកម្មភាពជាតិស្តីពីការទប់ស្កាត់អំពើហិង្សាលើស្ត្រីលើកទី ២ (២០១៤-២០១៨) បានចាត់អាទិភាពលើការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាឱ្យបានគ្រប់ជ្រុងជ្រោយដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាពិសេសការកែលម្អឱ្យកាន់តែប្រសើរនូវការសម្របសម្រួល និងសេវាបញ្ជូនជនរងគ្រោះឱ្យកាន់តែល្អប្រសើរឡើងរវាងស្ថាប័នផ្តល់សេវានានា។[6]

ការរៀបចំគោលការណ៍ណែនាំស្តីពីការបញ្ជូនជនរងគ្រោះនេះ គឺផ្អែកលើការស្រាវជ្រាវ និងការពិគ្រោះយោបល់ជាមួយអ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងដំណើរការចម្រុះ។ នៅក្នុងដំណាក់កាល

---

4 http://www.who.int/reproductivehealth/publications/violence/VAW_infographic.pdf?ua=1

5 MoWA (២០០២)។ ការសិក្សាអំពីលទ្ធភាពនៃការបង្កើតនូវមជ្ឈមណ្ឌលប្រមូលផ្តុំសេវាតាមច្រកចេញចូលតែមួយ។ ភ្នំពេញ ប្រទេសកម្ពុជា។

6 MoWA (២០០២)។ ការសិក្សាអំពីលទ្ធភាពនៃការបង្កើតនូវមជ្ឈមណ្ឌលប្រមូលផ្តុំសេវាតាមច្រកចេញចូលតែមួយ។ ភ្នំពេញ ប្រទេសកម្ពុជា។

ដំបូងនៃគម្រោងលទ្ធភាពទទួលបានយុត្តិធម៌សម្រាប់ស្ត្រីឆ្នាំ ២០១១-២០១៣ **(ATJW I)** ដែលបានអនុវត្តរួមគ្នា ដោយក្រសួងកិច្ចការនារីនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការ ជីអាយហ្សិត[7] ការសិក្សាជាមូលដ្ឋានមួយត្រូវបានធ្វើឡើង។ ការធ្វើអង្កេតនេះ បានពិនិត្យមើលអំពីគុណភាពនៃសេវាដែលបានផ្តល់ដោយស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ នៅក្នុងខេត្តចំនួន២នៃព្រះរាជាណាចក្រកម្ពុជា គឺ ខេត្តសៀមរាប និងខេត្តកំពង់ធំ។ ការសិក្សានេះ បង្ហាញថា ការបញ្ជូនជនរងគ្រោះមានបញ្ហាក្នុងចំណោមស្ថាប័នរដ្ឋ និងមិនមែនរដ្ឋនៅស្ទើរគ្រប់កម្រិតទាំងអស់។ ការពិគ្រោះយោបល់បន្ទាប់ទៀតត្រូវបានរៀបចំឡើងដើម្បីស្វែងយល់ពីបទពិសោធន៍នៅក្នុងការផ្តល់សេវា និងការបញ្ជូននានាជាមួយអ្នកផ្តល់សេវានៅក្នុងរង្វង់អង្គការមិនមែនរដ្ឋាភិបាល និងស្ថាប័នរដ្ឋ នៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដែលធ្វើការពាក់ព័ន្ធនិងអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ការសិក្សានេះ បានជួយឱ្យមានការយល់ដឹងអំពីការអនុវត្តក្នុងពេលបច្ចុប្បន្ន និងកំណត់នូវវិធីសាស្ត្រ សម្រាប់ការបញ្ជូនជនរងគ្រោះជាថ្មី។ លទ្ធផលនៃការសិក្សាទាំង ២ បានជួយដល់ការរៀបចំនូវសេចក្តីព្រាងគោលការណ៍ណែនាំនេះ។

នៅក្នុងដំណាក់កាលទី២ នៃគម្រោង **ATJW** (២០១៤-២០១៦)[8] ដំណើរការប្រមូលព័ត៌មានលើកទីបី ផ្តោតលើការស្វែងយល់អំពីការកត់ត្រាករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រដោយ ការិយាល័យកិច្ចការនារីស្រុក គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ (គ.ក.ស.ក)និងអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀតនៅក្នុងខេត្តគោលដៅដដែល។ ផ្អែកលើការពិគ្រោះយោបល់ទាំងនេះ សេចក្តីព្រាងគោលការណ៍ណែនាំនេះ ត្រូវបានបញ្ចប់នៅក្នុងកិច្ចប្រជុំ ពិគ្រោះយោបល់ដែលមានលក្ខណៈចូលរួមតាមរយៈសហគមន៍អ្នកអនុវត្ត និងជាមួយអ្នកពាក់ព័ន្ធសំខាន់ៗផ្សេងទៀត។

គោលការណ៍ណែនាំនេះ ស្របតាមគោលការណ៍ណែនាំ និងបទដ្ឋានជាតិ និងអន្តរជាតិទាក់ទងនឹងសិទ្ធិមនុស្សរបស់ស្ត្រី ដូចមានបញ្ជាក់នៅក្នុងផ្នែកទី ២ ហើយក៏ស្របជាមួយបទដ្ឋានអប្បបរមាដទៃ ទៀតរបស់ប្រទេសកម្ពុជា ដែលមានបញ្ជាក់នៅក្នុងផ្នែកទី ៣។ គោលការណ៍ណែនាំនេះ គូសបញ្ជាក់នៅក្នុងផ្នែកទី៣ អំពីការទទួលខុសត្រូវរបស់អ្នកផ្តល់សេវា នៅពេលធ្វើការបញ្ជូន និងទទួលជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ នៅក្នុងឧបសម្ព័ន្ធនៃឯកសារនេះ មានបញ្ចូលនូវគំរូនៃទម្រង់ចុះបញ្ជីករណី និងទម្រង់បញ្ជូន ដែលត្រូវប្រើដោយអ្នកផ្តល់សេវា ដើម្បីធានានូវភាពស៊ីសង្វាក់គ្នា និងគុណភាពនៃការចងក្រងជាឯកសារ ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដើម្បីគាំទ្រនូវការគ្រប់គ្រងករណីប្រកបដោយប្រសិទ្ធភាព។

7 គាំទ្រដោយមូលនិធិរបស់ក្រសួងសហព័ន្ធអាល្លឺម៉ង់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសហប្រតិបត្តិការ (BMZ) និងទីភ្នាក់ងារអេស្ប៉ាញសម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ (AECID)។

8 គាំទ្រដោយ BMZ និងសហហិរញ្ញវត្ថុដោយអង្គការជំនួយអូស្ត្រាលី។

## ១.២ វិសាលភាពនៃគោលការណ៍ណែនាំ

ការបញ្ជូនជនរងគ្រោះទៅរកសេវា គឺជាផ្នែកមួយនៃដំណើរការគ្រប់គ្រងករណីប្រកបដោយស្តង់ដារ (សូមអានឧបសម្ព័ន្ធ ៥) រាល់អ្នកផ្តល់សេវាទាំងអស់ រំពឹងថានឹងអនុវត្តតាមដំណើរការនេះ។ នៅក្នុងប្រទេសកម្ពុជា ការសិក្សាស្រាវជ្រាវបានបង្ហាញថា ការបញ្ជូនជនរងគ្រោះនៅក្នុងរង្វង់ស្ថាប័ន និងអន្តរស្ថាប័នខ្វះនូវគោលការណ៍ណែនាំដ៏ច្បាស់លាស់ ហើយចំនួននៅមានកម្រិតនៅឡើយ ដែលបណ្តាលឱ្យជនរងគ្រោះមិនទទួលបានសេវានានាដែលពួកគេត្រូវការជាចាំបាច់។

គោលការណ៍ណែនាំនេះ មានគោលបំណងតម្រង់ទិសដល់ការអនុវត្តការបញ្ជូនរបស់អ្នកផ្តល់សេវា ទាំងអស់ ដែលធ្វើការជាមួយស្ត្រីជាជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកូនរបស់ពួកគេ ជាពិសេសជនរងគ្រោះដោយអំពើហិង្សាដោយដៃគូស្និទ្ធស្នាល (រួមទាំងអំពើហិង្សាក្នុងគ្រួសារដែលប្រព្រឹត្តដោយសហព័ទ្ធ) និងអំពើហិង្សាផ្លូវភេទ។

អ្នកផ្តល់សេវា ទាំងស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ រួមមានអង្គភាពក្នុងជួររដ្ឋាភិបាល អង្គការជំនួយផ្នែកច្បាប់ មណ្ឌលសុវត្ថិភាព អ្នកផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រនៅសហគមន៍ អ្នកផ្តល់សេវាផ្នែកចិត្តសង្គម ក្រុមអ្នកស្ម័គ្រចិត្ត និងអ្នកពាក់ព័ន្ធដទៃទៀត[9]។

អ្នកផ្តល់សេវាជាស្ថាប័នរដ្ឋ និងមិនមែនរដ្ឋទាំងអស់ ត្រូវបានគ្របដណ្តប់ដោយសៀវភៅគោលការណ៍ណែនាំនេះ មានជាអាទិ៍ អ្នកប្រឹក្សាយោបល់ អ្នកផ្តល់ការថែទាំ អ្នកគ្រប់គ្រងករណីវេជ្ជបណ្ឌិត គិលានុបដ្ឋាក/គិលានុបដ្ឋាយិកា អ្នកស្ម័គ្រចិត្ត មេធាវី អាជ្ញាធរមូលដ្ឋាន (នគរបាលសមាជិកក្រុមប្រឹក្សាឃុំ ជាដើម) អ្នកសម្ភាសន៍ករណី អ្នកសម្របសម្រួលកម្មវិធី និងបុគ្គលពាក់ព័ន្ធដទៃទៀត។

## ១.៣ ចំណុចខ្វះខាតនៃគោលការណ៍ណែនាំ

គោលការណ៍ណែនាំនេះ មិនបានផ្តល់ការណែនាំសម្រាប់ដំណើរការគ្រប់គ្រងករណីទាំងមូលនោះទេ ក៏ប៉ុន្តែ គោលការណ៍នេះ ផ្តល់នូវការណែនាំសម្រាប់ការបញ្ជូនជនរងគ្រោះនៅក្នុងរង្វង់ និងរវាងអន្តរអ្នកផ្តល់សេវានៃស្ថាប័ននានា។ ការបញ្ជូនជនរងគ្រោះប្រកបដោយប្រសិទ្ធភាពមានសារៈសំខាន់ណាស់សម្រាប់ការគ្រប់គ្រងករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលមានប្រសិទ្ធភាព។ លើសពីនេះ គោលការណ៍ណែនាំនេះមិនបានគ្របដណ្តប់លើតម្រូវការជាក់លាក់របស់ជនរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ដែលជាកុមារឡើយ។ ការគាំទ្រលើតម្រូវការរបស់ជនរងគ្រោះជាកុមារប្រកបដោយការទទួលខុសត្រូវ និងមានប្រសិទ្ធភាព តម្រូវឱ្យអ្នកផ្តល់សេវាពាក់ព័ន្ធ មានការគិតគូរបន្ថែមទៀត។

---

៩ គេត្រូវទទួលស្គាល់ថា អ្នកស្ម័គ្រចិត្តខ្លះរបស់អង្គការមិនមែនរដ្ឋាភិបាលអាចចេញពីប្រភពច្រើន (ឧទាហរណ៍ សមាជិកក្រុមប្រឹក្សាឃុំ)។

# ផ្នែកទី ២ គោលការណ៍ណែនាំសម្រាប់ អ្នកផ្តល់សេវា នៅពេលបញ្ជូន និងទទួលជនរងគ្រោះ[10]

នៅពេលបញ្ជូន ឬទទួលជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ អ្នកផ្តល់សេវាត្រូវអនុវត្តតាមគោលការណ៍ណែនាំដូចខាងក្រោម៖

## ការគោរពសិទ្ធិមនុស្ស

អំពើហិង្សាទាក់ទងនឹងយេនឌ័រ គឺជាការរំលោភសិទ្ធិមនុស្ស ហើយជាអំពើដែលមិនអាចទទួលយកបានទោះនៅក្នុងទម្រង់ណាក៏ដោយ។

## ការធានាសុវត្ថិភាព

អាទិភាពទី ១ គឺសុវត្ថិភាពរបស់ជនរងគ្រោះ។ រាល់សកម្មភាពទាំងអស់ គឺសំដៅស្តារឡើងវិញ ឬរក្សានូវសុវត្ថិភាព និងមិនធ្វើឱ្យជនរងគ្រោះស្ថិតនៅក្នុងស្ថានភាពគ្រោះថ្នាក់កាន់តែរីកសាយធំនោះទេ។

## ការពង្រឹងភាពអង់អាចជាក់ស្តែង

ការផ្តល់នូវព័ត៌មានអំពីជម្រើសទាំងឡាយ អាចជួយជនរងគ្រោះឱ្យចេះធ្វើការជ្រើសរើសដោយខ្លួន ពួកគេផ្ទាល់។ ត្រូវស្តាប់នូវគំនិតយោបល់ និងការយល់ឃើញរបស់ជនរងគ្រោះ ហើយត្រូវធ្វើការដោះស្រាយដោយការគោរព។ នេះគេហៅថា ការប្រើវិធីសាស្ត្រពង្រឹងភាពអង់អាចរបស់ជនរងគ្រោះ ឬវិធីសាស្ត្រដែលមានការគិតគូរខ្ពស់ចំពោះជនរងគ្រោះ។ ខណៈពេលដែលព័ត៌មានអាចជួយឱ្យជនរងគ្រោះចេះធ្វើសេចក្តីសម្រេចចិត្តដោយខ្លួនឯង ហើយជនរងគ្រោះមានសិទ្ធិសម្រេចថាតើជំនួយអ្វីខ្លះ ដែលពួកគេចង់បាន ហើយពួកគេអាចបដិសេធនូវសេវាទាំងឡាយដែលមិនត្រូវតាមតម្រូវការរបស់ពួកគេ។

---

10 ដកស្រង់ចេញពី MoWA (២០១៦) សេចក្តីព្រាងបទដ្ឋានអប្បបរមាអំពីការផ្តល់សេវាកម្មប្រឹក្សាយោបល់បឋម។

## ឥរិយាបថមិនស្តីបន្ទោស និងមិនធ្វើការវិនិច្ឆ័យ

ជនរងគ្រោះដោយអំពើហិង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល អំពើហិង្សាផ្លូវភេទ ឬអំពើហិង្សាផ្សេងទៀត នឹងមិនត្រូវទទួលនូវការស្តីបន្ទោសចំពោះអំពើហិង្សានោះឡើយ។ អំពើហិង្សាលើស្ត្រីជាអំពើល្មើសច្បាប់របស់កម្ពុជា ហើយជនល្មើសត្រូវទទួលខុសត្រូវ។

## ឯកជនភាព និងការសម្ងាត់

គ្រប់ពេលទាំងអស់ ត្រូវមានការគោរពចំពោះភាពឯកជន និងការសម្ងាត់របស់ជនរងគ្រោះ និងគ្រួសាររបស់ពួកគេ។ ត្រូវផ្តល់សេវានៅទីកន្លែងដែលស្ងៀមស្ងាត់ មានលក្ខណៈឯកជន។ នៅពេល ដែលជនរងគ្រោះរៀបរាប់ប្រាប់ដោយអំពើហិង្សា ត្រូវស្នើសុំឱ្យអ្នកដទៃដែលនៅក្បែរនោះចាកចេញ ឬ ចាកចេញទៅកាន់កន្លែងផ្សេងទៀត ដើម្បីកុំឱ្យមានការស្តាប់ឮ។ ធ្វើបែបនេះគេអាចការពារបាននូវភាពឯកជនរបស់ជនរងគ្រោះ។

មិនត្រូវចែករំលែក ឬពិភាក្សាអំពីអត្តសញ្ញាណរបស់ជនរងគ្រោះនៅក្នុងអង្គប្រជុំណាមួយ ឬជាមួយអ្នកផ្តល់សេវាផ្សេងទៀតទាំងនៅខាងក្នុង ឬខាងក្រៅស្ថាប័ន ដោយមិនមានការអនុញ្ញាតពីជនរងគ្រោះឡើយ។ ចំពោះការពិគ្រោះយោបល់ ឬការផ្តល់នូវដំបូន្មានពីរបៀបគ្រប់គ្រងករណីពីអ្នកផ្តល់សេវាម្នាក់ទៀត មិនត្រូវប្រើឈ្មោះរបស់ជនរងគ្រោះឡើយ លើកលែងតែមានការអនុញ្ញាត។

## ការមិនរើសអើង

ជនរងគ្រោះទាំងអស់មានសិទ្ធិស្មើគ្នា ហើយត្រូវទទួលនូវការជួយដូចៗគ្នា និងមានសិទ្ធិទទួលនូវសេវាប្រកបដោយភាពស្មើៗគ្នា។ មិនត្រូវមានការរើសអើង ឬការប្រព្រឹត្តផ្សេងគ្នាចំពោះជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ណាមួយឡើយ ដោយសារតែជាតិពន្ធុ សាសនា វណ្ណៈសង្គម ពិការភាព អាយុ ចំណង់ចំណូលចិត្តផ្លូវភេទ ឬ កត្តាផ្សេងទៀត។

# ផ្នែកទី ៣ បទដ្ឋានអប្បបរមា និង គោលការណ៍ណែនាំដែល ពាក់ព័ន្ធនានានៅប្រទេសកម្ពុជា

ប្រទេសកម្ពុជា មានបទដ្ឋានអប្បបរមា និងគោលការណ៍ណែនាំមួយចំនួនដែលពាក់ព័ន្ធសម្រាប់អ្នកផ្តល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ។ ឯកសារទាំងនេះ ត្រូវបានសិក្សាឡើងវិញដើម្បីធានាថា គោលការណ៍ណែនាំស្តីពីការបញ្ជូនជនរងគ្រោះនេះ មានលក្ខណៈសមស្រប និងជួយតម្រង់ទិសដល់ការរៀបចំនូវយន្តការអនុវត្តន៍ និងយន្តការពិនិត្យតាមដាន។

បទដ្ឋាន និងគោលការណ៍ណែនាំដែលមានការពាក់ព័ន្ធជាមួយការឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ទាំងនោះមាន៖

- សៀវភៅណែនាំស្តីពីកិច្ចការពារផ្លូវច្បាប់សម្រាប់សិទ្ធិស្ត្រី និងកុមារនៅកម្ពុជា (ក្រសួងកិច្ចការនារី ឆ្នាំ២០១៤)
- គោលការណ៍ណែនាំថ្នាក់ជាតិសម្រាប់ប្រព័ន្ធសុខាភិបាលស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រីនិងកុមារ (ក្រសួងសុខាភិបាលឆ្នាំ ២០១៥) និងសៀវភៅគ្លីនិក៖ ការថែទាំសុខភាពសម្រាប់ស្ត្រីរងគ្រោះដោយសារអំពើហិង្សាពីដៃគូស្និទ្ធស្នាលឬអំពើហិង្សាផ្លូវភេទ (រៀបចំដោយក្រសួងសុខាភិបាលដែលនឹងត្រូវអនុវត្តក្នុងឆ្នាំ ២០១៦)
- បទដ្ឋានអប្បបរមាសម្រាប់ការប្រឹក្សាជាមូលដ្ឋានដល់ស្ត្រី និងក្មេងស្រីជាជនរងគ្រោះដោយអំពើហិង្សា និងការរំលោភបំពាន រៀបចំដោយក្រសួងកិច្ចការនារី និងក្រសួងសុខាភិបាល ដែលនឹងបញ្ចប់ក្នុងឆ្នាំ ២០១៦
- គោលនយោបាយ និងបទដ្ឋានអប្បបរមាសម្រាប់ការការពារជនរងគ្រោះដោយអំពើជួញដូរមនុស្ស (ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឆ្នាំ ២០០៩)
- បទដ្ឋានអប្បបរមាសម្រាប់ការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទដែលស្នាក់នៅក្នុងមណ្ឌល (សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឆ្នាំ ២០១៤)
- បទដ្ឋានអប្បបរមាស្តីពីការថែទាំជំនួសចំពោះកុមារ (សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឆ្នាំ ២០០៨)។

# ផ្នែកទី ៤ តួនាទី និងការទទួលខុសត្រូវ សម្រាប់ការបញ្ជូនជនរងគ្រោះ ដោយអំពើហិង្សាទាក់ទងនឹង យេនឌ័រ និងកូនរបស់ពួកគេ

ផ្នែកនេះ ចែងអំពីភារកិច្ច និងតួនាទីដ៏ជាក់លាក់សម្រាប់អ្នកផ្តល់សេវាទាំងឡាយ នៅពេលទទួល និងបញ្ជូនជនរងគ្រោះនៅក្នុងអង្គការរបស់ខ្លួន (ខាងក្នុងស្ថាប័ន) និងទៅកាន់សេវាផ្សេងទៀត (អន្តរស្ថាប័ន) នៅខាងក្រៅស្ថាប័ន ឬអង្គការរបស់ខ្លួន។

ការទទួលខុសត្រូវដែលរៀបរាប់ខាងក្រោម មិនស្ថិតតាមលំដាប់លំដោយនោះទេ។ តួនាទី និងការទទួលខុសត្រូវខ្លះ ផ្តល់នូវការណែនាំអំពីការបញ្ជូននៅក្នុងអង្គការ ហើយការណែនាំខ្លះបង្ហាញអំពីការបញ្ជូនជនរងគ្រោះទៅសេវានៅខាងក្រៅ។

## ៤.១ តួនាទីរបស់ស្ថាប័នសម្របសម្រួល

*ប្រព័ន្ធបញ្ជូនជនរងគ្រោះ* តម្រូវឱ្យមានអ្នកសម្របសម្រួល ដើម្បីធ្វើការសម្របសម្រួលទំនាក់ទំនងរវាងស្ថាប័នផ្សេងៗនៅក្នុងប្រព័ន្ធនេះ ដើម្បីធានាឱ្យមានលំហូរករណី។ នៅពេលដែលមានការចូលរួមពីសំណាក់អ្នកផ្តល់សេវាមកពីពហុវិស័យ ដែលមានជំនាញផ្សេងៗគ្នា ចាំបាច់ត្រូវធានានូវលំហូរនៃការបញ្ជូន និងធ្វើការកំណត់នូវអត្តសញ្ញាណ ការទប់ស្កាត់ ឬការដោះស្រាយនូវចំណុចជាប់គាំង នៅក្នុងការឆ្លើយតបសម្រាប់ការផ្តល់សេវាជាប្រព័ន្ធនេះ។

អ្នកគ្រប់គ្រងករណីមកពីស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ ត្រូវទទួលខុសត្រូវក្នុងការធានាឱ្យមានការបញ្ជូនជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ជាស្ត្រី និងកូនរបស់ពួកគេ។ ដូច្នេះរាល់អ្នកផ្តល់សេវាទាំងអស់ដែលពាក់ព័ន្ធនៅក្នុងការបញ្ជូនជនរងគ្រោះ និងផ្តល់សេវា ត្រូវសហការគ្នាទៅវិញទៅមក និងធ្វើការដើម្បីឧត្តមប្រយោជន៍របស់ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកូនរបស់ពួកគេ។

មន្ទីរកិច្ចការនារីខេត្ត ត្រូវមានតួនាទីសម្របសម្រួលជាមួយអ្នកផ្តល់សេវានៃស្ថាប័នរដ្ឋ និងមិនមែនរដ្ឋដើម្បីធានានូវប្រព័ន្ធបញ្ជូនប្រកបដោយប្រសិទ្ធភាព។ មន្ទីរកិច្ចការនារីខេត្ត មានការទទួលខុសត្រូវ ដូចខាងក្រោម៖

- ធ្វើការសម្របសម្រួលលំហូរនៃការបញ្ជូនជនរងគ្រោះ ដើម្បីធានាថាជនរងគ្រោះបានទទួលនូវសេវាដែលពួកគេត្រូវការ រួមទាំងការធ្វើអន្តរាគមន៍ដើម្បីស្វែងរកដំណោះស្រាយចំពោះចំណុចជាប់គាំងដែលបានកើតឡើង ឧទាហរណ៍ នៅក្នុងតុលាការ ឬជាមួយនគរបាល។
- ធ្វើការពិនិត្យតាមដានប្រព័ន្ធបញ្ជូនជនរងគ្រោះ ដើម្បីធានាថា ជនរងគ្រោះត្រូវបានបញ្ជូនទៅកាន់សេវាដែលពួកគេត្រូវការ (ស្របជាមួយគោលការណ៍ណែនាំនេះ) ដោយសមាជិកទាំងអស់នៅក្នុងប្រព័ន្ធបញ្ជូននេះ និងធានាថា អ្នកផ្តល់សេវានៅក្នុងប្រព័ន្ធបញ្ជូននេះ បានធ្វើរបាយការណ៍អំពីស្ថានភាពនៃករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រនីមួយៗ ទន្ទឹមនឹងធ្វើការការពារ និងរក្សាការសម្ងាត់ជូនជនរងគ្រោះផងដែរ។
- កោះប្រជុំបណ្តាញអ្នកផ្តល់សេវាឱ្យបានទៀងទាត់ យ៉ាងហោចណាស់ម្តងរៀងរាល់ ៣ខែ។
- រៀបចំ និងចែកចាយនូវសៀវភៅទំនាក់ទំនងរបស់អ្នកផ្តល់សេវា ដែលមានបញ្ចូលនូវប្រភេទនៃសេវា និងព័ត៌មានទំនាក់ទំនង (ដោយធ្វើបច្ចុប្បន្នភាពជាទៀងទាត់)។

## ៤.២ ជំនាញរបស់អ្នកផ្តល់សេវា និងការបញ្ជូនដោយផ្អែកលើការវាយតម្លៃអំពីតម្រូវការ

ជាញឹកញាប់ អ្នកផ្តល់សេវាមានជំនាញនៅក្នុងសេវាដ៏ជាក់លាក់មួយ ឬមានអាណត្តិដ៏ជាក់លាក់មួយ។ អ្នកផ្តល់សេវា ត្រូវដឹងអំពីចំណុចខ្វះខាតអំពីសេវាកម្មរបស់ខ្លួន។ ការយល់ដឹងនេះមិនទាក់ទងនិងការបំពេញការងារមិនបានល្អរបស់ស្ថាប័ននោះឡើយ តែគឺជាការបង្ហាញឱ្យឃើញពីការទទួលស្គាល់នូវជំនាញផ្តល់សេវារបស់ខ្លួនផ្ទាល់ និងការយល់ដឹងពីសេវាផ្សេងៗទៀត។

ជាផ្នែកមួយនៃដំណើរការប្រឹក្សាយោបល់ជាមូលដ្ឋាន អ្នកផ្តល់សេវា ត្រូវធ្វើការវាយតម្លៃអំពីតម្រូវការជាមូលដ្ឋានជាមួយជនរងគ្រោះ ដោយផ្តល់នូវព័ត៌មានអំពីជម្រើសដែលមានបន្ថែមពីលើ សេវាដែលជាជំនាញរបស់ខ្លួន។ ការផ្តល់នូវព័ត៌មានគ្រប់គ្រាន់អំពីជម្រើសនានា គឺជាការជួយ

ពង្រឹងជនរងគ្រោះឱ្យចេះធ្វើការជ្រើសរើសយកជំនួយ ដែលស្ត្រីរងគ្រោះចង់បានដោយផ្អែកលើតម្រូវការរបស់នាងផ្ទាល់។

នៅក្នុងការពិចារណានានា ត្រូវបញ្ចូលជាបន្ទាន់នូវបញ្ហាសុវត្ថិភាពរបស់ជនរងគ្រោះ និងកូនរបស់ពួកគេ និង តម្រូវការផ្នែកថែទាំសុខភាពបន្ទាន់ (សូមអាន ៤.៦ និង ៤.៧)។ ការវាយតម្លៃអំពីតម្រូវការបន្ថែមទៀត ត្រូវបញ្ចូលនូវតំណាងខាងផ្លូវច្បាប់ និង/ឬការបញ្ជូនទៅរកសេវាផ្លូវច្បាប់ ជម្រកសុវត្ថិភាព ការប្រឹក្សាយោបល់ ការគាំទ្រពេលមានអាសន្ន និងតម្រូវការផ្សេងទៀតទៅតាមអ្វីដែលបានពិគ្រោះយោបល់ជាមួយជនរងគ្រោះ[11]។

បន្ទាប់មក អ្នកផ្ដល់សេវាអាចបញ្ជូន ជនរងគ្រោះទៅអ្នកផ្ដល់សេវាផ្សេងទៀត ប្រសិនបើស្ថាប័ន/ អង្គការរបស់ខ្លួនមិនមានសេវាផ្ដល់ឱ្យទៅតាមសំណើសុំរបស់ជនរងគ្រោះទេនោះ។ ជនរងគ្រោះខ្លួនឯង ត្រូវយល់ព្រមនូវរាល់ការបញ្ជូនទៅកាន់សេវាទាំងអស់នោះ។

## ៤.៣ ការសម្របសម្រួលបញ្ជូនជនរងគ្រោះនៅក្នុងរង្វង់ស្ថាប័នតែមួយ

ជនរងគ្រោះ មានសិទ្ធិទទួលព័ត៌មានអំពីជម្រើសនានា ដែលមាននៅក្នុងស្ថាប័ន[12]។ អ្នកផ្ដល់សេវានីមួយៗ ដែលផ្ដល់សេវាដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវធ្វើការសម្របសម្រួលការបញ្ជូននៅក្នុងរង្វង់ស្ថាប័នរបស់ខ្លួន (ឧទាហរណ៍ រវាងនាយកដ្ឋានផ្សេងៗគ្នា) តាមរយៈការវាយតម្លៃករណី ការធ្វើផែនការ និងការបញ្ជូនជនរងគ្រោះដោយផ្អែកលើតម្រូវការរបស់ពួកគេ។

នៅក្នុងស្ថាប័ន ត្រូវមានការគោរពភាពជាឯកជនរបស់ជនរងគ្រោះ ហើយព័ត៌មានរបស់ពួកគេត្រូវរក្សាជាការសម្ងាត់[13]។ ព័ត៌មានអាចត្រូវបានចែករំលែកជាមួយអ្នកដទៃនៅក្នុងស្ថាប័ន របស់ខ្លួនតែប៉ុណ្ណោះ នៅពេលដែលជនរងគ្រោះត្រូវការសេវាពីអង្គការនោះ។

នៅពេលដែលជនរងគ្រោះត្រូវបានបញ្ជូនផ្ទៃក្នុងបែបនេះ រាល់ការធ្វើទំនាក់ទំនងព័ត៌មានទាំងអស់ត្រូវតែច្បាស់។ ធ្វើបែបនេះដើម្បីបញ្ចៀសនូវការសាកសួរច្រើនលើកច្រើនសារនូវព័ត៌មាន

11 MoWA និង MoH (២០១៦). បទដ្ឋានទី ៣ នៃបទដ្ឋានអប្បបរមាអំពីការផ្ដល់សេវាកម្មប្រឹក្សាយោបល់បឋម ភ្នំពេញ ប្រទេសកម្ពុជា។

12 MoWA និង MoH (២០១៦). បទដ្ឋានទី ៣ នៃបទដ្ឋានអប្បបរមាអំពីការផ្ដល់សេវាកម្មប្រឹក្សាយោបល់បឋម ភ្នំពេញ ប្រទេសកម្ពុជា។

13 MoWA និង MoH (២០១៦). បទដ្ឋានទី ៥ នៃបទដ្ឋានអប្បបរមាអំពីការផ្ដល់សេវាកម្មប្រឹក្សាយោបល់បឋម ភ្នំពេញ ប្រទេសកម្ពុជា។

ដដែលៗទៅលើ ជនរងគ្រោះពីផ្នែកផ្សេងទៀត ដោយសារការធ្វើបែបនេះ គឺអាចបណ្តាលឱ្យជនរងគ្រោះមានការភ័យខ្លាចម្តងទៀត (trauma)។ ទោះជាយ៉ាងណាក៏ដោយ អ្នកផ្តល់សេវានៅផ្នែកនីមួយៗ អាចបញ្ជាក់ឡើងវិញនូវព័ត៌មានពីតម្រូវការក្រៅពីនេះ ជាមួយជនរងគ្រោះ ហើយផ្តល់យោបល់ឱ្យមានការបញ្ជូនទៅរកសេវាផ្សេងទៀត ប្រសិនបើចាំបាច់។

ជនបង្គោល ឬអ្នកគ្រប់គ្រងករណីនៅក្នុងស្ថាប័ននីមួយៗ គួរតែជាអ្នកទទួលខុសត្រូវដើម្បីធានាឱ្យមានលំហូរព័ត៌មានដោយរលូន។

## ៤.៤ ការសម្របសម្រួលបញ្ជូនរវាងអន្តរស្ថាប័នដោយប្រើទម្រង់ចុះបញ្ជីករណី និងទម្រង់បញ្ជូន

អ្នកផ្តល់សេវានៅក្នុងប្រព័ន្ធបញ្ជូនជនរងគ្រោះទាំងអស់ ត្រូវប្រមូលនូវព័ត៌មានអប្បបរមាដូចៗគ្នា ដោយប្រើប្រាស់នូវទម្រង់ចុះបញ្ជីករណីសម្រាប់ករណីអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងអស់។ ព័ត៌មានបន្ថែមអាចត្រូវបានប្រមូលដោយអ្នកផ្តល់សេវានីមួយៗ ដើម្បីគាំទ្រដល់ការគ្រប់គ្រងករណី និងការផ្តល់សេវាប្រកបដោយប្រសិទ្ធភាពខ្ពស់។ គំរូនៃទម្រង់ចុះបញ្ជីករណី គឺជាទម្រង់គំរូមួយដែលកត់ត្រានូវព័ត៌មានអប្បបរមាអំពីជនរងគ្រោះ។

ដំណើរការចុះបញ្ជីករណីនេះ អាចជួយផ្ទៀងផ្ទាត់ព័ត៌មានពីស្ថាប័នមួយទៅស្ថាប័នមួយទៀត តែតម្រូវឱ្យមានព័ត៌មានជាអប្បបរមាសម្រាប់ធ្វើការបញ្ជូន ដើម្បីឱ្យអង្គការទទួលអាចឆ្លើយតបចំពោះតម្រូវការរបស់ជនរងគ្រោះ និងរួមចំណែកធ្វើឱ្យជនល្មើសទទួលខុសត្រូវចំពោះអំពើល្មើសរបស់ពួកគេឱ្យបានកាន់តែច្រើន។ ការបំពេញនូវទម្រង់ចុះបញ្ជីករណី និងការចែករំលែកទម្រង់នេះជាមួយភ្នាក់ងារផ្តល់សេវាទទួលជនរងគ្រោះដែលបានបញ្ជូនមក រារាំងនូវការរៀបរាប់ រឿងរ៉ាវដដែលៗរបស់ជនរងគ្រោះ ដែលធ្វើបែបនេះគឺជាការកាត់បន្ថយនូវការរងគ្រោះម្តងទៀតរបស់អ្នកទាំងនោះ។

*ទម្រង់ចុះបញ្ជីករណី* (សូមអានឧបសម្ព័ន្ធ ១)[14] ត្រូវតែផ្តល់ទៅឱ្យស្ថាប័នទទួលជនរងគ្រោះ និងត្រូវផ្ញើទៅជាមួយជនរងគ្រោះដោយដាក់ក្នុងស្រោមសំបុត្របិទជិត ឬផ្ញើតាមអ្នកដែលអមដំណើរជាមួយជនរងគ្រោះទៅឱ្យស្ថាប័នដែលទទួលការបញ្ជូននោះ។

---

14 ស្ថាប័ន/អង្គការអាចប្រើប្រាស់នូវទម្រង់ផ្ទាល់ខ្លួនរបស់ខ្លួន ប្រសិនបើទម្រង់នោះមានបញ្ចូលនូវព័ត៌មានទាំងអស់ ដូចមាននៅក្នុងឧបសម្ព័ន្ធ ១។

ជាមួយទម្រង់ចុះបញ្ជីករណីនេះ *មានទម្រង់បញ្ជូនមួយ*ទៀត (សូមអានឧបសម្ព័ន្ធ ២) ដែលត្រូវតែបំពេញ និងផ្ញើទៅស្ថាប័នទទួល ដើម្បីឱ្យស្ថាប័ននេះ បានទទួលព័ត៌មានច្បាស់លាស់អំពីតម្រូវការរបស់ជនរងគ្រោះ។

បន្ទាប់មក ស្ថាប័នទទួលបំពេញនូវ*ទម្រង់ផ្តល់យោបល់ត្រឡប់អំពីការបញ្ជូន* (សូមអានឧបសម្ព័ន្ធ ៣) ដែលត្រូវផ្ញើត្រឡប់ទៅអ្នកផ្តល់សេវា ដែលបានធ្វើការបញ្ជូនពីដំបូង។ ដំណើរការនេះ អាចឱ្យអ្នកផ្តល់សេវានីមួយៗធ្វើការតាមដានបន្តនូវការបញ្ជូន និងទទួលនូវព័ត៌មានថាតើការបញ្ជូនត្រូវបានបញ្ចប់ហើយ ឬយ៉ាងណា និងថាតើជនរងគ្រោះ បានទទួលនូវសេវាដែលពួកគេត្រូវការរួចរាល់ហើយឬយ៉ាងណា។

ក្រៅពីនេះ ដើម្បីចងក្រងជាឯកសារអំពីការបញ្ជូន មាន*ទម្រង់នៃសេចក្តីសង្ខេបអំពីការបញ្ជូនករណីមួយទៀត* (សូមអានឧបសម្ព័ន្ធ ៤) ដែលត្រូវបានផ្តល់ឱ្យដើម្បីប្រមូលនូវព័ត៌មានពីស្ថាប័ននីមួយៗ អំពីរាល់ការបញ្ជូនទាំងអស់សម្រាប់ករណីនីមួយៗ។

សម្រាប់ទាំងបុគ្គលិក និងជនរងគ្រោះ ត្រូវតែមានមធ្យោបាយដឹកជញ្ជូនដ៏សមស្រប។ ប្រសិនបើអាច ត្រូវស្វែងរកជំនួយពីភាគីទី ៣ ឧទាហរណ៍ មិត្តភក្តិ ឬសមាជិកគ្រួសាររបស់ជនរងគ្រោះឱ្យជួយ។

## ៤.៥ ការចាត់តាំងជនបង្គោលតាមស្ថាប័នទទួល

អ្នកផ្តល់សេវានីមួយៗ ត្រូវចាត់តាំងបុគ្គលិកម្នាក់ដែលបំពេញតួនាទីជា៖ ១) ជនបង្គោលដំបូងគេសម្រាប់ធ្វើទំនាក់ទំនងជាមួយជនរងគ្រោះ ២) អ្នកគ្រប់គ្រងករណី និង ៣) ជនបង្គោលសម្រាប់ធ្វើការបញ្ជូន។ ទីភ្នាក់ងារផ្តល់សេវា ប្រគល់តួនាទីទាំងបីនេះដល់បុគ្គលិកដដែល។

បុគ្គលិកដែលមានតួនាទីដ៏សំខាន់ទាំងបីនេះ ត្រូវទទួលការបណ្តុះបណ្តាលអំពីបទដ្ឋានអប្បបរមា ស្តីពីការប្រឹក្សាយោបល់ជាមូលដ្ឋាន និងត្រូវមានសមត្ថភាពក្នុងការផ្តល់នូវព័ត៌មាន និងធ្វើការបញ្ជូនជនរងគ្រោះទៅរកសេវាផ្សេងទៀតប្រកបដោយប្រសិទ្ធភាព បន្ថែមពីលើជំនាញស្នូលរបស់ពួកគេ[15]។

---

15 MoWA និង MoH (២០១៦)។ បទដ្ឋានអប្បបរមាអំពីការផ្តល់សេវាកម្មប្រឹក្សាយោបល់បឋមភ្នំពេញ ប្រទេសកម្ពុជា។

## ៤.៦ ការធ្វើអន្តរាគមន៍ពេលមានវិបត្តិ និងការបញ្ជូនទៅរកសេវាថែទាំសុខភាព

រាល់អ្នកផ្តល់សេវាទាំងអស់ ត្រូវធ្វើការសម្របសម្រួលឱ្យទទួលបាននូវសេវាថែទាំផ្នែកវេជ្ជសាស្ត្រជាបន្ទាន់សម្រាប់ជនរងគ្រោះដែលមានរបួសស្នាមទៅតាមតម្រូវការផ្ទាល់ខ្លួនរបស់ពួកគេ។

ជនរងគ្រោះដោយអំពើហិង្សាលើស្ត្រីដែលរងរបួសគួរត្រូវបានប្រាប់អំពីជម្រើសនៃការធ្វើ *លិខិតបញ្ជាក់វេជ្ជសាស្ត្រ* ដែលបានកត់ត្រាអំពីរបួសស្នាមរបស់ជនរងគ្រោះសម្រាប់ធ្វើការបញ្ជូនទៅរកសេវាផ្លូវច្បាប់។ លិខិតបញ្ជាក់វេជ្ជសាស្ត្រនេះ កត់ត្រាអំពីរបួសស្នាម និងបន្ទាប់មកអាចប្រើសម្រាប់ធ្វើការចោទប្រកាន់ចំពោះជនមុខសញ្ញា និងសម្រាប់កត់ត្រាទុកជាឯកសារដោយអំពើហិង្សាក្នុងគ្រួសារ។

ជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ គួរត្រូវប្រាប់ផងដែរអំពីព័ត៌មានទាក់ទងនឹងសិទ្ធិទទួលបានការធ្វើកោសលវិច័យភ្លាមៗ ហើយដែលស្របតាមការយល់ព្រមរបស់នាង ដូចមានរៀបរាប់នៅក្នុងគោលការណ៍ជាតិស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រីនៅក្នុងប្រព័ន្ធសុខាភិបាល។ ការធ្វើកោសលវិច័យ គឺជាការពិនិត្យ ដែលមានលក្ខណៈជាប្រព័ន្ធមួយ ធ្វើនៅមន្ទីរពេទ្យបង្អែក ដែលពិនិត្យផ្នែកវេជ្ជសាស្ត្រ ផ្តល់ការថែទាំសុខភាពបន្ទាន់ និងប្រមូលភស្តុតាងសម្រាប់សកម្មភាពនៃវិធានការផ្លូវច្បាប់។ ជនរងគ្រោះ គួរត្រូវប្រាប់អំពីការឆ្លងជម្ងឺកាមរោគ និងការទប់ស្កាត់មេរោគអេដស៍/ជម្ងឺអេដស៍ ការពារបន្ទាន់កុំឱ្យមានផ្ទៃពោះ និងការប្រមូលភស្តុតាងសម្រាប់ការធ្វើកោសលវិច័យ ដែលមានប្រសិទ្ធភាពត្រឹមអំឡុងពេល ៧២ម៉ោង ក្រោយការរំលោភបំពាននោះ។[16]

ប្រសិនបើជនរងគ្រោះដោយអំពើហិង្សាផ្លូវភេទ មិនយល់ព្រមចំពោះការធ្វើកោសលវិច័យទេនោះ នាងគួរត្រូវបានប្រាប់អំពីសារៈសំខាន់នៃការពិនិត្យផ្នែកវេជ្ជសាស្ត្រ និងសិទ្ធិទទួលបានការថែទាំសុខភាពបន្ទាន់ ការទប់ស្កាត់ការឆ្លងជម្ងឺកាមរោគ និងមេរោគអេដស៍/ជម្ងឺអេដស៍ និងការពារបន្ទាន់កុំឱ្យមានផ្ទៃពោះផងដែរ។ រាល់ការព្យាបាលនិងថែទាំទាំងអស់ត្រូវមានការយល់ព្រមពីជនរងគ្រោះជាមុនសិន។

16 MoH (២០១៤) គោលការណ៍ណែនាំថ្នាក់ជាតិស្តីពីការគ្រប់គ្រងអំពើហិង្សាលើស្ត្រី និងកុមារនៅក្នុងប្រព័ន្ធសុខាភិបាល។ ភ្នំពេញ ប្រទេសកម្ពុជា។

## ៤.៧ ការផ្តល់សុវត្ថិភាពជាបន្ទាន់សម្រាប់ជនរងគ្រោះ និងកូនរបស់ពួកគេ ព្រមទាំងអ្នកផ្តល់សេវា

ការយកចិត្តទុកដាក់សម្រាប់ការផ្តល់សុវត្ថិភាពដល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកូនរបស់ពួកគេ គួរតែជាអាទិភាពខ្ពស់របស់អ្នកផ្តល់សេវានានា។ ការវាយតម្លៃអំពីហានិភ័យ និងវិធានការបន្ថែមដើម្បីធានានូវសុវត្ថិភាពបន្ទាន់មួយសម្រាប់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកូនរបស់ពួកគេ ត្រូវរៀបចំធ្វើដោយអនុលោមតាមបទដ្ឋានអប្បបរមាស្តីពីការប្រឹក្សាយោបល់ជាមូលដ្ឋានដូចខាងក្រោម៖[17]

ប្រសិនបើពុំមានពិធីសារផ្សេងទេ សំណួរមួយចំនួនដែលត្រូវសួរមាន៖

- តើជនល្មើសនៅតែជាការគំរាមកំហែងមែនទេនៅពេលនេះ? (ប្រសិនបើមែន គួរតែជម្រាបបញ្ហានេះដល់នគរបាល)។
- តើអំពើហិង្សាកើតឡើងកាន់តែញឹកញាប់មែនទេក្នុងរយៈពេល ៦ខែចុងក្រោយនេះ?
- តើជនល្មើសបានប្រើអាវុធ ឬគំរាមដោយអាវុធមែនទេ?
- តើអ្នកធ្លាប់ត្រូវបានវាយដំនៅពេលអ្នកមានផ្ទៃពោះដែរឬទេ?
- តើជនល្មើសប្រច័ណ្ឌខ្លាំងជាមួយអ្នកមែនទេ?

ប្រសិនបើស្ត្រីឆ្លើយថា ចាស ចំពោះសំណួរខាងលើយ៉ាងហោចណាស់ ៣ មានន័យថា នាងអាចមិនមានសុវត្ថិភាពចំពោះការត្រឡប់ទៅផ្ទះរបស់គាត់វិញ។

ប្រសិនបើស្ត្រី និងកូនៗរបស់គាត់ ត្រូវបានចាត់ក្នុងស្ថានភាពមានហានិភ័យខ្ពស់ដែលនៅតែបន្តរងហិង្សាពីជនមុខសញ្ញានោះ នគរបាលឬអាជ្ញាធរទទួលខុសត្រូវដទៃទៀត គួរត្រូវបានជូនព័ត៌មានជាបន្ទាន់។

បើសិនជាស្ត្រី បដិសេធក្នុងការជូនព័ត៌មានទៅអាជ្ញាធរនានា ផែនការសុវត្ថិភាពជាបន្ទាន់មួយដើម្បីធានាសុវត្ថិភាព គួរត្រូវបានធ្វើឡើង។ ជម្រើសនានា ដូចជា ការបញ្ជូនទៅរកជម្រក

17 MoWA និង MoH (២០១៦)។ បទដ្ឋានទី ២ នៃបទដ្ឋានអប្បបរមាអំពីការផ្តល់សេវាកម្មប្រឹក្សាយោបល់បឋម។ ភ្នំពេញ ប្រទេសកម្ពុជា។

សុវត្ថិភាព បញ្ជូនទៅស្នាក់នៅក្នុងផ្ទះសាច់ញាតិ ឬមិត្តភក្តិ ឬនៅកន្លែងសុវត្ថិភាពផ្សេងទៀតតាមការជ្រើសរើសរបស់នាង។

ប្រសិនបើអ្នកផ្តល់សេវាគិតថា កូនៗស្ថិតក្នុងការថែទាំបន្ទាន់របស់ជនរងគ្រោះ មានហានិភ័យពីការប្រើអំពើហិង្សានោះ អាជ្ញាធរមូលដ្ឋានដែលនៅជិតបំផុត រួមមាន មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ឬភ្នាក់ងារនគរបាល គួរទំនាក់ទំនង ដើម្បីផ្តល់សុវត្ថិភាពដល់កុមារដែលនៅក្នុងបន្ទុកទាំងនោះ។

អ្នកផ្តល់សេវាក៏ត្រូវធ្វើការវាយតម្លៃអំពីសុវត្ថិភាពបន្ទាន់ផ្ទាល់ខ្លួនរបស់ខ្លួនផងដែរ។ ចំពោះមូលហេតុផ្សេងៗទៀត រាប់ទាំងសុវត្ថិភាពផងដែរ ជនរងគ្រោះ គួរជូនដំណើរទៅកាន់ស្ថាប័នបញ្ជូន បើអាចធ្វើបាន។ សុវត្ថិភាពផ្លូវចិត្ត និងផ្លូវកាយរបស់ជនរងគ្រោះ គួរត្រូវបានការធានាពីសំណាក់ទីភ្នាក់ងារបញ្ជូន នៅពេលធ្វើការបញ្ជូន ជាពិសេស ក្នុងករណីដែលបុគ្គលិកជូនដំណើរជាបុរស ហើយជនរងគ្រោះជាស្ត្រី ឬជាកុមារ។ ស្ថាប័នក៏ត្រូវធានាពីសុវត្ថិភាពផ្លូវចិត្ត និងផ្លូវកាយរបស់បុគ្គលិកដែលអមដំណើរជនរងគ្រោះនោះផងដែរ។

## ៤.៨ ការណែនាំ និងការគ្រប់គ្រងក្រុមសហគមន៍ និងអ្នកស្ម័គ្រចិត្ត

អ្នកផ្តល់សេវាដែលត្រូវបានជួយគាំទ្រដោយអ្នកស្ម័គ្រចិត្ត ឬក្រុមសហគមន៍ត្រូវមានគោលនយោបាយដ៏ច្បាស់លាស់អំពីតួនាទី និងការទទួលខុសត្រូវរបស់អ្នកស្ម័គ្រចិត្តនៅក្នុងការផ្តល់សេវា។

អ្នកស្ម័គ្រចិត្ត ឬក្រុមសហគមន៍អាចមានសមត្ថភាពខុសៗគ្នានៅក្នុងការឆ្លើយតបចំពោះអំពើហិង្សាទាក់ទងនឹងយេនឌ័រ ហើយពួកគេត្រូវទទួលបាននូវការបណ្តុះបណ្តាលអំពីបទដ្ឋានអប្បបរមាស្តីពី ការប្រឹក្សាយោបល់ផ្លូវចិត្តជាមូលដ្ឋាន និងគោលការណ៍ណែនាំអំពីការបញ្ជូននេះ។

## ៤.៩ ការតាមដានបន្តបន្ទាប់ពីការបញ្ជូន

ក្រៅពីដំណើរការគ្រប់គ្រងករណីតាមលក្ខណៈ និងដើម្បីកែលំអគុណភាពនៃការបញ្ជូនអ្នកផ្តល់សេវា ត្រូវធ្វើការតាមដានជនរងគ្រោះបន្តបន្ទាប់ពីបញ្ជូនពួកគេទៅអ្នកផ្តល់សេវាផ្សេងទៀត។ ការតាមដានបន្ត ផ្តល់នូវឱកាសឱ្យមានការរៀនសូត្រថាតើ ការបញ្ជូននេះមានប្រសិទ្ធភាពឬយ៉ាងណា និងផ្តល់ឱកាសឱ្យមានការវាយតម្លៃថាតើ ជនរងគ្រោះត្រូវការសេវាបន្ថែមទៀតឬយ៉ាងណាដោយផ្អែកលើព័ត៌មានដែលបានផ្តល់ឱ្យ និងការយល់ព្រមពីជនរងគ្រោះ។ ជនរង

គ្រោះអាចរក្សាសិទ្ធិក្នុងការសម្រេច ទទួលយកសេវា និង/ឬជំនួយដែលពួកគេត្រូវការ និងអាចបដិសេធសេវាណាមួយ។

## ៤.១០ ការផ្តល់សេវាត្រូវផ្អែកទៅលើប្រភេទផ្សេងៗនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ

អំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានកំណត់និយមន័យថាជា "អំពើហិង្សាដែលប្រព្រឹត្តទៅលើស្ត្រីម្នាក់ពីព្រោះតែគាត់ជាមនុស្សស្រី ឬដែលប៉ះពាល់ស្ត្រីនោះដោយចំពោះ។ អំពើទាំងនេះ រួមមានអំពើដែលបង្កឱ្យមានការឈឺចាប់ ការប្បូសស្នាមលើរាងកាយ ផ្លូវចិត្ត ឬផ្លូវភេទ ឬការឈឺចាប់ ការគំរាមកំហែងនៃអំពើទាំងនោះ ការបង្ខិតបង្ខំ និងការដកហូតសេរីភាពផ្សេងទៀត"។

នៅក្នុងប្រទេសកម្ពុជា អំពើហិង្សាទាក់ទងនឹងយេនឌ័រ ជារួមមាន អំពើហិង្សាដែលប្រព្រឹត្តដោយ ដៃគូស្និទ្ធស្នាល អំពើហិង្សាក្នុងគ្រួសារ និងអំពើហិង្សាផ្លូវភេទ។ អ្នកផ្តល់សេវាត្រូវដឹងអំពីជម្រើសទាំងឡាយ រួមទាំងសេវាសម្រាប់ជួយដល់ជនរងគ្រោះដែលទទួលរងនូវប្រភេទណាមួយនៃអំពើហិង្សាទាំងនេះ ហើយផ្តល់សេវា និងបញ្ជូនទៅតាមករណីនីមួយៗ។ ប្រភេទនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ នឹងមានផលប៉ះពាល់មកលើតម្រូវការរបស់ជនរងគ្រោះ និងការងារបញ្ជូនជនរងគ្រោះ (ឧទាហរណ៍ ដូចបានពន្យល់ខាងដើម យើងត្រូវប្រាប់ជនរងគ្រោះពីអំពើរំលោភសេពសន្ថវៈអំពីការធ្វើកោសលវិច័យ និងភាពចាំបាច់នៃការថែទាំបន្ទាន់ផ្នែកវេជ្ជសាស្ត្រ)។

ប្រភេទនៃអំពើហិង្សាទាក់ទងនឹងយេនឌ័រ ត្រូវបានបែងចែកផ្សេងគ្នានៅក្នុងទម្រង់ចុះបញ្ជីករណី ទៅតាមអំពើហិង្សាផ្លូវភេទ អំពើហិង្សាក្នុងគ្រួសារ ឬអំពើហិង្សាប្រព្រឹត្តដោយដៃគូស្និទ្ធស្នាល។ នេះជាកិច្ចការសំខាន់ណាស់ក្នុងការកត់សម្គាល់ថា ការកំណត់នេះ ត្រូវផ្អែកលើរបាយការណ៍របស់ជនរងគ្រោះ មិនមែនផ្អែកលើការកំណត់នៃបទល្មើសតាមផ្លូវច្បាប់នោះទេ។

*អំពើហិង្សាផ្លូវភេទ៖* ការរុកកួនផ្លូវភេទ អំពើបង្ហាញកេរភេទ អំពើប្រទូស្តកេរខ្មាស អំពើរំលោភសេពសន្ថវៈ។

*អំពើហិង្សាដោយដៃគូស្និទ្ធស្នាល ឬអំពើហិង្សាក្នុងគ្រួសារ៖* អំពើហិង្សាលើរាងកាយ អំពើហិង្សាផ្លូវភេទ អំពើហិង្សាផ្លូវចិត្ត អំពើហិង្សាដោយពាក្យសំដី និងអំពើហិង្សាផ្នែកសេដ្ឋកិច្ច។

*អំពើហិង្សាផ្សេងទៀត៖* ប្រភេទនៃអំពើហិង្សាផ្សេងទៀត ត្រូវបានបង្ហាញនៅក្នុងទម្រង់ស្រង់ព័ត៌មាន ដើម្បីរក្សាទុកជាឯកសារដោយអំពើហិង្សាផ្សេងទៀតទាក់ទងនឹងយេនឌ័រប្រឆាំងស្ត្រីដែលមិនបានរៀបរាប់ខាងលើ។

# ឧបសម្ព័ន្ធ ១ – ទម្រង់ចុះបញ្ជីករណី

(សូមរក្សាជាសម្ងាត់ សូមកុំផ្សព្វផ្សាយនូវឯកសារនេះ ទម្រង់នេះត្រូវថតចម្លងទុក១ច្បាប់សម្រាប់ស្ថាប័នទទួល)

លេខសំណុំរឿង៖.........................................

<table>
<tr><td colspan="4">ផ្នែកទី I - ព័ត៌មានដំបូង</td></tr>
<tr><td colspan="4">ក- ព័ត៌មានអំពីជនរងគ្រោះ/ដើមបណ្តឹងរដ្ឋប្បវេណី/ដើមចោទ</td></tr>
<tr><td colspan="3">ឈ្មោះជនរងគ្រោះ៖</td><td>ភេទ៖ ប្រុស ☐ ស្រី ☐</td></tr>
<tr><td colspan="2">ថ្ងៃខែឆ្នាំកំណើត៖</td><td>អាយុ៖</td><td rowspan="4">ស្ថានភាពគ្រួសារ៖<br>រៀបការ ☐<br>នៅលីវ ☐<br>លែងលះ ☐<br>មេម៉ាយ ☐<br>ផ្សេងៗ (សូមបញ្ជាក់)............</td></tr>
<tr><td colspan="3">ទីកន្លែងកំណើត៖</td></tr>
<tr><td>ជនជាតិ៖</td><td colspan="2">សញ្ជាតិ៖</td></tr>
<tr><td>កម្រិតវប្បធម៌៖ ................</td><td colspan="2">មុខរបរ៖..................</td></tr>
<tr><td colspan="4">ចំនួនកូនសរុប...........................នាក់ ស្រី........................នាក់</td></tr>
<tr><td colspan="2">១.ឈ្មោះ..................ភេទ.......អាយុ........ឆ្នាំ<br>២.ឈ្មោះ..................ភេទ.......អាយុ.........ឆ្នាំ<br>៣.ឈ្មោះ..................ភេទ.......អាយុ.........ឆ្នាំ</td><td colspan="2">៤.ឈ្មោះ.................ភេទ.......អាយុ.........ឆ្នាំ<br>៥.ឈ្មោះ.................ភេទ.......អាយុ.........ឆ្នាំ<br>៦.ឈ្មោះ.................ភេទ.......អាយុ.........ឆ្នាំ</td></tr>
<tr><td colspan="4">តើជនរងគ្រោះមានពិការភាពដែរឬទេ? មាន ☐ ទេ ☐<br>បើមាន សូមបញ្ជាក់ប្រភេទនៃពិការភាពនោះ:.......................................................</td></tr>
</table>

| | |
|---|---|
| អាសយដ្ឋានជនរងគ្រោះ៖ | លេខទំនាក់ទំនងជនរងគ្រោះ៖ |
| (ករណីជនរងគ្រោះជាកុមារ)<br>ឈ្មោះរបស់ឪពុក ☐ /ម្តាយ ☐ ឬអ្នកថែរក្សា ឬអាណាព្យាបាល៖ ........................................... | |
| អាសយដ្ឋាន៖ | លេខទូរស័ព្ទទំនាក់ទំនង៖ |

| ខ- ឧបទ្ទវហេតុ | | | |
|---|---|---|---|
| ប្រភេទនៃអំពើហិង្សាទាក់ទងនិងយេនឌ័រ អ្នកអាចគូសយកជម្រើសច្រើនជាង ១ | | | |
| ☐ អំពើហិង្សាផ្លូវភេទ | | | |
| ☐ អំពើរុកកួនខាងផ្លូវភេទ | ☐ អំពើបង្ហាញកេរភេទ | ☐ អំពើប្រទូស្តកេរខ្មាស | ☐ រំលោភសេពសន្ថវៈ |
| ☐ អំពើហិង្សាដោយដៃគូស្និទ្ធស្នាល ឬអំពើហិង្សាក្នុងគ្រួសារ | | | |
| ☐ ផ្លូវកាយ | ☐ ផ្លូវភេទ | ☐ ផ្លូវចិត្ត | ☐ សេដ្ឋកិច្ច |
| ☐ ផ្សេងទៀតសូមរៀបរាប់៖.................................................................................... | | | |

| | | |
|---|---|---|
| ទីកន្លែងកើតហេតុ៖<br>................................ | កាលបរិច្ឆេទ៖<br>.................... | ពេលវេលាកើតហេតុ៖<br>............................................ |

ពណ៌នាអំពីអង្គហេតុ (សង្ខេបអំពីហេតុការណ៍ដែលបានកើតឡើងជាក់ស្តែង និងអ្វីដែលបានកើតឡើងក្រោយមកទៀត) បើចាំបាច់សរសេររៀបរាប់នៅទំព័របន្ថែម។ សម្រាប់ករណីអំពើហិង្សាក្នុងគ្រួសារ សូមបញ្ជាក់ពេលវេលានៃអំពើហិង្សា (អំពើហិង្សាបានចាប់ផ្តើមតាំងពីខែ/ឆ្នាំណាមក?)

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

**ប្តឹងទាមទារ/បទល្មើសដែលត្រូវចោទ៖**

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

## គ- ព័ត៌មានអំពីជនសង្ស័យ/ចុងចម្លើយ

ចំនួនជនសង្ស័យ៖..................................នាក់

១.ឈ្មោះ៖ .......................ភេទ.........អាយុ......
ជនជាតិ៖............សញ្ជាតិ...........មុខរបរ៖.......
ស្ថានភាពគ្រួសារ៖រៀបការ ☐ នៅលីវ ☐ មេម៉ាយ ☐
អាសយដ្ឋាន៖..............................................
..................................................................
ទំនាក់ទំនងជាមួយជនរងគ្រោះ:.......................
..................................................................

២.ឈ្មោះ៖ .....................ភេទ.........អាយុ......
ជនជាតិ៖........សញ្ជាតិ........មុខរបរ៖............
ស្ថានភាពគ្រួសារ៖រៀបការ ☐ នៅលីវ ☐ មេម៉ាយ☐
អាសយដ្ឋាន៖..............................................
..................................................................
ទំនាក់ទំនងជាមួយជនរងគ្រោះ:.......................
..................................................................

៣.ឈ្មោះ៖ .........................ភេទ.........អាយុ....
ជនជាតិ៖............សញ្ជាតិ...........មុខរបរ៖.......
ស្ថានភាពគ្រួសារ៖ រៀបការ ☐ នៅលីវ ☐ មេម៉ាយ☐
អាសយដ្ឋាន៖..............................................
..................................................................
ទំនាក់ទំនងជាមួយជនរងគ្រោះ:.......................
..................................................................

៤.ឈ្មោះ៖ ..............ភេទ........អាយុ.............
ជនជាតិ៖.......សញ្ជាតិ.......មុខរបរ៖..............
ស្ថានភាពគ្រួសារ៖ រៀបការ ☐ នៅលីវ ☐ មេម៉ាយ☐
អាសយដ្ឋាន៖..............................................
..................................................................
ទំនាក់ទំនងជាមួយជនរងគ្រោះ:.......................
..................................................................

៥.ឈ្មោះ៖ .........................ភេទ.....................អាយុ.................ជនជាតិ៖.............................
សញ្ជាតិ..................... ស្ថានភាពគ្រួសារ៖ រៀបការ ☐ នៅលីវ ☐ មេម៉ាយ ☐
អាសយដ្ឋាន៖.........................................................................................................
មុខរបរ៖................................................................................................................
ទំនាក់ទំនងជាមួយជនរងគ្រោះ:..........................................................................

ក្នុងករណីមិនស្គាល់ជនសង្ស័យ ពណ៌នាអំពីជនសង្ស័យនោះ ដោយបង្ហាញកិនភាគសំគាល់ផ្សេងៗ៖

តើជនសង្ស័យនៅតែបន្តគំរាមកំហែងទៀតដែរឬទេ? បាទ/ចាស ☐ ទេ ☐

បើសិនជាមាន សូមជួយណែនាំជនរងគ្រោះរៀបចំផែនការសម្រាប់សុវត្ថិភាព

ក្នុងករណីជនសង្ស័យជាកុមារ ផ្តល់ឈ្មោះឪពុកម្តាយ/អ្នកថែរក្សា/អាណាព្យាបាល៖ ........................
..........................................................................................................................

| អាសយដ្ឋាន ៖ | ត្រូវជាអ្វីនឹងជនសង្ស័យ ៖............................... |
|---|---|
| | លេខទូរស័ព្ទទំនាក់ទំនង ៖.............................. |

| ឃ- សាក្សី (ប្រើទំព័របន្ថែម ប្រសិនបើចាំបាច់) | |
|---|---|
| ឈ្មោះ អាសយដ្ឋាន និងលេខទំនាក់ទំនង ៖ | រៀបរាប់ព្រឹត្តិការណ៍ដែលបានមើលឃើញ ៖ |
| | |

| ង- សកម្មភាពដែលបានចាត់ការ ឬសេវាដែលបានទទួលមុនពេលសម្ភាសន៍ជនរងគ្រោះ | | |
|---|---|---|
| តើឧបទ្ទវហេតុនេះ ធ្លាប់បានរាយការណ៍ទៅណាហើយឬនៅ? | បាទ/ចាស ☐ | ទេ ☐ |
| តើឧបទ្ទវហេតុនេះ បានរាយការណ៍ទៅអ្នកណា? | កាលបរិច្ឆេទ | ការឆ្លើយតបចំពោះការរាយការណ៍ |
| នគរបាល/កងរាជអាវុធហត្ថ<br>ឈ្មោះ និងអាសយដ្ឋាន ៖ | | |
| អាជ្ញាធរមូលដ្ឋាន (ឧ. ក្រុមប្រឹក្សាឃុំ/សង្កាត់ ប្រធានភូមិ)<br>ឈ្មោះ និងអាសយដ្ឋាន ៖ | | |
| ភ្នាក់ងារនគរបាលយុត្តិធម៌ ៖ .......................<br>ឈ្មោះ និងអាសយដ្ឋាន ៖ | | |

<table>
<tr><td>ផ្សេងទៀត៖ ..........................................<br>ឈ្មោះ និងអាសយដ្ឋាន៖</td><td></td><td></td></tr>
<tr><td colspan="3">តើជនរងគ្រោះធ្លាប់បានទទួលសេវាសង្គមកិច្ចណាមួយហើយឬនៅ? បាទ/ចាស ☐ ទេ ☐</td></tr>
<tr><th>ប្រភេទនៃសេវា</th><th>កាលបរិច្ឆេទ</th><th>សេវាត្រូវបានផ្តល់ដោយ</th></tr>
<tr><td>ការពិគ្រោះយោបល់ផ្លូវចិត្ត ☐</td><td></td><td></td></tr>
<tr><td>ការពិគ្រោះយោបល់ផ្នែកច្បាប់ ☐</td><td></td><td></td></tr>
<tr><td>ការសង្គ្រោះផ្នែកវេជ្ជសាស្ត្រ ☐</td><td></td><td></td></tr>
<tr><td>ផ្សេងៗ៖.................................................</td><td></td><td></td></tr>
<tr><td colspan="3">តើអ្នកត្រូវការសេវាបន្ថែម ឬវិធានការចាំបាច់ផ្សេងៗទៀតដែរឬទេ? បាទ/ចាស ☐ ទេ ☐<br>(បើបាទ/ចាស) សូមមើលផ្នែកទី៤ សម្រាប់ការណែនាំអំពីការប៉ាន់ប្រម៉ាណតម្រូវការ និងផែនការនេះ</td></tr>
</table>

| ផ្នែកទី II - ការប៉ាន់ប្រមាណតម្រូវការ និងផែនការបញ្ជូនបន្ត | | | | | |
|---|---|---|---|---|---|
| តើជនរងគ្រោះចង់បានអ្វី/ត្រូវការអ្វី? សួរជនរងគ្រោះអំពីតម្រូវការក្នុងលំដាប់សេវានីមួយៗដូចមានរាយខាងក្រោម ហើយពន្យល់នាងអំពីជម្រើសនានាសម្រាប់សកម្មភាព/សេវានានា | | | | | |
| តម្រូវការបច្ចុប្បន្នរបស់ជនរងគ្រោះ | បើគេត្រូវការសូមគូស | ផែនការសកម្មភាពនានា (ថ្ងៃខែបំពេញទម្រង់នេះ) | | បើសិនបញ្ជូន តើអ្នកបញ្ជូនទៅស្ថាប័នណា? (សូមបញ្ជាក់ និងបំពេញក្នុងទម្រង់បញ្ជូន) | បញ្ជាក់ពីយោបល់/ការព្រួយបារម្ភរបស់ជនរងគ្រោះក្នុងលក្ខខណ្ឌពិសេសដើម្បីតាមដាន |
| | | ផ្តល់ឱ្យ | បញ្ជូនចេញ | | |
| សេវាសុខភាព | | | | | |
| សង្គ្រោះបន្ទាន់/ការរងរបួស | ☐ | | | | |
| ការធ្វើកោសលវិច័យ | ☐ | | | | |
| សេវាផ្នែកច្បាប់ | | | | | |
| ពិគ្រោះយោបល់ផ្នែកច្បាប់ | ☐ | | | | |
| ធ្វើជាតំណាងខាងផ្លូវច្បាប់ | ☐ | | | | |
| ការដាក់ពាក្យបណ្តឹង | ☐ | | | | |
| ផ្សេងទៀត (បញ្ជាក់) ........................................ | ☐ | | | | |
| ផែនការសុវត្ថិភាព | | | | | |
| មណ្ឌលសុវត្ថិភាព | ☐ | | | | |
| មណ្ឌលសំចត | ☐ | | | | |

| | | | | | |
|---|---|---|---|---|---|
| ផ្សេងទៀត (បញ្ជាក់) ........................................ | ☐ | | | | |
| ការពិគ្រោះយោបល់ | | | | | |
| ពិគ្រោះយោបល់ផ្លូវចិត្ត រយៈពេលខ្លី | ☐ | | | | |
| ពិគ្រោះយោបល់ផ្លូវចិត្ត រយៈពេលវែង | ☐ | | | | |
| .ផ្សេងទៀត (បញ្ជាក់) ........................................ | ☐ | | | | |
| ផ្នែកសេដ្ឋកិច្ច | | | | | |
| ជំនួយតម្រូវការបន្ទាន់ | ☐ | | | | |
| ជំនាញ/បំណិនជីវិត | ☐ | | | | |
| ចូលរៀនវគ្គបណ្ដុះបណ្ដាលវិជ្ជាជីវៈ | ☐ | | | | |
| ផ្សេងទៀត (បញ្ជាក់) ........................................ | ☐ | | | | |

រៀបចំដោយ៖ កាលបរិច្ឆេទ៖

................................................ ................................................

អ្នកគ្រប់គ្រងករណីឬជនបង្គោលឬអ្នកសម្ភាសន៍

កាលបរិច្ឆេទ៖

................................................ ................................................

ឈ្មោះ និងហត្ថលេខាឬស្នាមមេដៃជនរងគ្រោះ

# ឧបសម្ព័ន្ធ ២–ទម្រង់បញ្ជូនជនរងគ្រោះ (ត្រូវបំពេញដោយស្ថាប័នបញ្ជូន)

រក្សាការសម្ងាត់ មិនត្រូវផ្សព្វផ្សាយឯកសារនេះជាមួយអ្នកដែលគ្មានការអនុញ្ញាត

| | |
|---|---|
| ការណែនាំ | ទម្រង់នេះត្រូវបំពេញនៅពេលធ្វើការបញ្ជូនអតិថិជនទៅរកសេវាផ្សេងទៀតក្រៅពីស្ថាប័នរបស់អ្នក។ សូមបញ្ជាក់ឱ្យជាក់លាក់ថាតើមានសេវាអ្វីខ្លះដែលបានស្នើសុំ។ ក្នុងនាមជាស្ថាប័នបញ្ជូន សូមផ្តល់នូវឯកសារដ៏សមស្របទាំងឡាយដល់ស្ថាប័នទទួលដើម្បីបំពេញការងាររបស់ពួកគេ។ សូមដាក់ទម្រង់នេះ នៅក្នុងស្រោមសំបុត្របិទជិតរួមជាមួយឯកសារផ្សេងទៀត រួចប្រគល់ឱ្យទៅជនរងគ្រោះ (ឬបុគ្គលិកដែលអមដំណើរជាមួយគាត់) ដើម្បីយកទៅប្រគល់ឱ្យស្ថាប័នទទួល។ បន្ទាប់ពីបំពេញទម្រង់បញ្ជូននេះ ហើយគួរថតចម្លងទុក១ច្បាប់ ហើយសូមបំពេញទម្រង់សង្ខេបនៃការបញ្ជូនករណី (ទម្រង់ទី ៤)។ |

១. លេខសំណុំរឿង ៖..........................................កាលបរិច្ឆេទបញ្ជូន ៖ ...............................

២. ប្រភេទនៃអំពើហិង្សា (សូមពិនិត្យមើលប្រភេទទាំងឡាយនៅក្នុងទម្រង់ចុះបញ្ជីករណី)៖

..................................................................................................................................

៣. ស្ថាប័នទទួល៖ ..............................អាសយដ្ឋានរបស់ស្ថាប័ន/អង្គការទទួល៖.....................

..................................................................................................................................

៤. ឈ្មោះអ្នកទំនាក់ទំនងរបស់ស្ថាប័ន/អង្គការទទួល៖ ........................................................

៥. ឈ្មោះជនរងគ្រោះ (ឬលេខកូដ)៖ ...................................អាយុ............. ភេទ..................

៦. អាសយដ្ឋានរបស់ជនរងគ្រោះ ........................................................................................

*(កុំបំពេញ ក្នុងករណីយល់ថា វាប៉ះពាល់ដល់សន្តិសុខរបស់ជនរងគ្រោះ)*

៧. ឈ្មោះគ្រួសារ/អាណាព្យាបាល៖................................លេខទូរស័ព្ទទំនាក់ទំនង.....................

៨.មូលហេតុនៃការបញ្ជូន....................................................................................................

៩.សេវាដែលស្នើសុំ...........................................................................................................

ភ្ជាប់ជាមួយនូវទម្រង់ទទួលជនរងគ្រោះ/របាយការណ៍/របាយការណ៍សង្ខេបព័ត៌មានរបស់ជនរងគ្រោះ សូមផ្ញើទម្រង់ផ្ដល់យោបល់ត្រឡប់ស្ដីពីការបញ្ជូនមកកាន់ស្ថាប័នបញ្ជូនវិញ តាមអាសយដ្ឋានខាងក្រោម៖

.................................................................................................................................

...............................................................................................................................

បញ្ជូនដោយ...............................................ទទួលដោយ.......................................

តួនាទី ..................................................តួនាទី ..............................................

កាលបរិច្ឆេទ.............................................កាលបរិច្ឆេទ.....................................

ហត្ថលេខា ..............................................ហត្ថលេខា ......................................

# ឧបសម្ព័ន្ធ ៣ – ទម្រង់ផ្តល់យោបល់ត្រឡប់ស្តីពីការបញ្ជូន (ត្រូវបំពេញដោយស្ថាប័នទទួល)

| រក្សាសម្ងាត់ មិនត្រូវផ្សព្វផ្សាយឯកសារនេះជាមួយអ្នកមិនមានភារកិច្ច |
|---|

| | |
|---|---|
| ការណែនាំ | ទម្រង់នេះត្រូវបំពេញដោយស្ថាប័នទទួល និងផ្ញើទៅឱ្យស្ថាប័នបញ្ជូន បន្ទាប់ពីសេវាត្រូវបានផ្តល់ឱ្យជនរងគ្រោះ។ សូមបំពេញថ្ងៃខែឆ្នាំដែល ជនរងគ្រោះបានមកជួបអ្នកនៅថ្ងៃដំបូង ក៏ដូចជា ថ្ងៃខែឆ្នាំ ដែលសេវាបានផ្តល់ឱ្យ។ យោបល់អំពីភាពពេញចិត្តរបស់ជនរងគ្រោះត្រូវតែបំពេញដោយអ្នកគ្រប់គ្រងករណីរបស់ជនរងគ្រោះប៉ុណ្ណោះ។ ទម្រង់នេះដាក់នៅក្នុងស្រោមសំបុត្របិទជិត និងអាចប្រគល់ឱ្យជនរងគ្រោះយកទៅឱ្យស្ថាប័នបញ្ជូន ឬផ្ញើទៅឱ្យស្ថាប័នបញ្ជូនតាមប្រៃសណីយ៍ ឬតាមមធ្យោបាយផ្សេង។ ព័ត៌មាននៅក្នុងទម្រង់នេះ នឹងជាផ្នែកមួយនៃប្រព័ន្ធទិន្នន័យ និងសម្រាប់ផ្តល់ធាតុចូលដល់ការប្រមូលទិន្នន័យ និងសម្រាប់ធ្វើរបាយការណ៍។ ដូច្នេះ ភាពសុក្រិតនៃព័ត៌មាននេះ មានសារសំខាន់ខ្លាំងណាស់។ កំណត់ចំណាំ៖ ស្ថាប័នបញ្ជូន ត្រូវតាមដានករណីនានាដែលបានបញ្ជូន យ៉ាងហោចណាស់ ២ខែម្តង បន្ទាប់ពីថ្ងៃបញ្ជូន។ |

ឈ្មោះស្ថាប័នទទួល ដែលផ្តល់យោបល់ត្រឡប់៖ ..............................................................កាលបរិច្ឆេទ៖..................................

| លេខសំណុំរឿង៖ | ប្រភេទអំពើហិង្សា៖ | ឈ្មោះជនរងគ្រោះ៖ | អាយុ៖ | ភេទ៖ |
|---|---|---|---|---|
| ឈ្មោះស្ថាប័ន ដែលត្រូវផ្ញើព័ត៌មានត្រឡប់ទៅ៖ | | | | |

| សេវាដែលបានស្នើសុំ | តើសេវាត្រូវបានផ្តល់ឱ្យដែរឬទេ ? | បុគ្គលិកដែលផ្តល់សេវា | កាលបរិច្ឆេទការផ្តល់សេវា | ព័ត៌មាន/យោបល់បន្ថែម (ឧ.បញ្ហាជួបប្រទះ) | យោបល់ពេញចិត្តរបស់ជនរងគ្រោះ (សម្រាប់តែអ្នកគ្រប់គ្រងករណីប៉ុណ្ណោះ) |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |

______________________

ហត្ថលេខាបុគ្គលិកនៃស្ថាប័នទទួល

# ឧបសម្ព័ន្ធ ៤ – ទម្រង់សង្ខេបនៃការបញ្ជូនករណី

រក្សាការសម្ងាត់ មិនត្រូវផ្សព្វផ្សាយឯកសារនេះជាមួយអ្នកដែលគ្មានភារកិច្ច

| | |
|---|---|
| ការណែនាំ | ទម្រង់នេះត្រូវបំពេញដោយស្ថាប័ននីមួយៗ ដើម្បីតាមដានការបញ្ជូនករណីទៅស្ថាប័នផ្សេងៗទៀត។ ប្រភពព័ត៌មានក្នុងទម្រង់នេះអាចយកចេញពីទម្រង់បញ្ជូនជនរងគ្រោះ( ទម្រង់២ ) និងទម្រង់ស្រង់យោបល់ត្រឡប់ស្តីពីការបញ្ជូន ( ទម្រង់៣ ) និងការតាមដានតាមរយៈរូបភាពផ្សេងទៀត។ |

លេខសំណុំរឿង ៖ .............................................. ឈ្មោះជនរងគ្រោះ ៖............................................... ប្រភេទអំពើហិង្សា ៖ ..................

| ឈ្មោះបុគ្គលិកបញ្ជូន | កាលបរិច្ឆេទបញ្ជូន | ស្ថាប័នទទួល | ឈ្មោះបុគ្គលិកទទួល | វិធានការ/សេវាដែលបានស្នើសុំ | កាលបរិច្ឆេទនៃការផ្តល់យោបល់ត្រឡប់ | យោបល់ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

ឈ្មោះ និងហត្ថលេខារបស់បុគ្គលិក (អ្នកដែលបានបំពេញទម្រង់នេះ)

## ឧបសម្ព័ន្ធ ៥ – ដំណើរការគ្រប់គ្រងករណី

ការគ្រប់គ្រងករណី ផ្តល់នូវក្របខណ្ឌមួយជាប្រព័ន្ធ សម្រាប់ភ្នាក់ងារ/អ្នកផ្តល់សេវា ដើម្បីផ្តោតលើតម្រូវការរបស់ជនរងគ្រោះ។ ដំណើរការនៃការគ្រប់គ្រងករណីចាប់ផ្តើម នៅពេលដែលជនរងគ្រោះ ត្រូវបានកំណត់ (រួមទាំងការដែលជនរងគ្រោះទៅរកសេវាដោយខ្លួនឯងផង) និងបញ្ចប់ទៅវិញនៅពេលដែលជនរងគ្រោះរស់នៅមានសុវត្ថិភាព បញ្ឈប់ពីសេវាកម្ម ឬ បំបែកចេញពីផ្ទះរបស់ពួកគាត់ ត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុងសហគមន៍វិញ សកម្មភាពជាដំណាក់កាលដូចមានរាយខាងក្រោម គឺជាទម្រង់ស្តង់ដានៃដំណើរការគ្រប់គ្រងករណីប្រកបដោយប្រសិទ្ធភាព៖

ការវាយតម្លៃករណី៖ សំដៅលើដំណើរការនៃការវាយតម្លៃស្ថានភាព និងកំណត់រកតម្រូវការរបស់ជនរងគ្រោះយោងតាមការយល់ព្រមរបស់នាង ហើយដែលអនុវត្តតាមការប្រឹក្សាយោបល់ជាមូលដ្ឋាន និងតាមគោលការណ៍នៃការបញ្ជូនជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រដូចបានរៀបរាប់ក្នុងឯកសារនេះស្រាប់។

ការវាយតម្លៃអំពីហានិភ័យ គឺជាដំណើរការនៃការធ្វើសេចក្តីសម្រេចដែលអ្នកផ្តល់សេវាត្រូវកំណត់នូវវិធានការដ៏ប្រសើរបំផុត តាមរយៈការប៉ាន់ស្មាន ការកំណត់អត្តសញ្ញាណ ការកំណត់អំពីចំនួន និងស្ថានភាពនៃហានិភ័យរបស់ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកូនរបស់ពួកគេ។ នេះគឺសំដៅលើ ភាពអាចកើតមានបន្ថែមទៀត និង/ឬភាពធ្ងន់ធ្ងរនៃអំពើហិង្សានោះ។ ក្នុងករណីដែលតម្រូវឱ្យមានការវាយតម្លៃអំពីហានិភ័យ ការវាយតម្លៃនេះគឺជាមូលដ្ឋានសម្រាប់កំណត់នូវវិធានការសន្តិសុខ ឬវិធានការការពារសម្រាប់ស្ត្រីរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងកូនរបស់ពួកគេ។

ការធ្វើអន្តរាគមន៍ ពេលមានវិបត្តិ៖ គឺជាដំណើរការនៃការឆ្លើយតបនូវជំនួយបន្ទាន់រយៈពេលខ្លីដល់ជនរងគ្រោះ។ ការឆ្លើយតបនេះ រាប់ទាំង ការធ្វើផែនការសុវត្ថិភាព និងការគាំពារសុខភាពបន្ទាន់។ កិច្ចការនេះ អាចមានតម្រូវការនៃការបញ្ជូនបន្តជាបន្ទាន់ទៅរកសេវាផ្សេងទៀត។

ការធ្វើផែនការករណី៖ គឺជាដំណើរការមួយដែលភ្នាក់ងារ/អ្នកផ្តល់សេវា ធ្វើការរួមគ្នាជាមួយជនរងគ្រោះដើម្បីរៀបចំជាផែនការជីវិត/ផែនការអនាគត ដោយយោងតាមផែនការក្នុងការធ្វើអន្តរាគមន៍។ ផែនការ ត្រូវកំណត់នូវគោលដៅសម្រាប់ដោះស្រាយនូវបញ្ហា និងតម្រូវការ ដែលបានកំណត់រួមគ្នារវាង អ្នកផ្តល់សេវា និងជនរងគ្រោះ រាប់បញ្ចូលទាំងផែនការធ្វើអន្តរាគម ការ

ផ្តល់សេវានានា និងការបញ្ជូន។ ការធ្វើផែនការករណី គឺផ្អែកលើការវាយតម្លៃរួមគ្នា និងត្រូវតែសិក្សាឡើងវិញក្នុងកំឡុងពេលកំណត់ណាមួយ ដើម្បីពិនិត្យមើលពីវឌ្ឍនភាពឆ្ពោះទៅរកការធ្វើឱ្យសម្រេចគោលដៅ។

ការបញ្ជូនជនរងគ្រោះ៖ គឺជាដំណើរការមួយនៃការបញ្ជូនជនរងគ្រោះទៅរកសេវាដ៏សមស្រប។

ការសះជា៖ គឺជាដំណើរការនៃការដែលអ្នកផ្តល់សេវា អនុវត្តផែនការករណី ជាមួយជនរងគ្រោះ។ មិនមែនរាល់ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រទាំងអស់ បានឆ្លងកាត់បទពិសោធន៍ដូចៗគ្នានោះទេ ហើយនឹងទទួលបានសេវាផ្សេងៗគ្នាយោងតាមស្ថានភាពរបស់ពួកគេរៀងៗខ្លួន។ ជនរងគ្រោះ អាចចាត់ថាសះជាទៅបាន លុះត្រាតែ នាងឈប់មានតម្រូវការ/ចេតនាស្វែងរកសេវានានានោះឯង។

ការធ្វើសមាហរណកម្ម៖ គឺជាដំណើរការមួយនៃការវិលត្រឡប់ទៅរស់នៅក្នុងសហគមន៍តាមការជ្រើសរើសរបស់ជនរងគ្រោះ បើសិនជានាងធ្លាប់បានរស់នៅក្នុងមណ្ឌលថែទាំ ឬក៏បានចេញឆ្ងាយពីផ្ទះរបស់នាង។ ការធ្វើសមាហរណកម្មដ៏ជោគជ័យ គឺជាគោលដៅដែលស្ត្រី ចាកចេញពីមណ្ឌលថែទាំ។ ដូច្នេះ រាល់ការធ្វើផែនការករណី គួរតែធ្វើតាមជំហានៗឆ្ពោះទៅរកការរស់នៅដោយគ្មានខ្លួនឯងបានដោយមិនពឹងផ្អែកលើជំនួយ។

ការតាមដានករណី៖ សំដៅលើដំណើរការដែលសេវាកម្មនានា ត្រូវបានផ្តល់ជូនកន្លងមក។ សកម្មភាពនេះ អាចធ្វើទៅបាន បន្ទាប់ពីសេវាកម្មណាមួយ ត្រូវបានផ្តល់ឱ្យ រាប់ទាំងការស្នាក់នៅក្នុងមណ្ឌលថែទាំ។

ការបិទករណី៖ គឺជាដំណើរការមួយដែលការគាំទ្រនិងការផ្តល់សេវាជូនជនរងគ្រោះ ត្រូវបានបញ្ឈប់ ដោយមានការពិគ្រោះយោបល់ជាមួយជនរងគ្រោះ និងពិភាក្សាអំពីតម្រូវការរបស់ពួកគេរួចមក។ ករណីនេះ អាចនឹងត្រូវបើកឡើងវិញ ប្រសិនបើចាំបាច់។

សម្រាប់ជនរងគ្រោះដែលត្រូវបានធ្វើសមាហរណកម្មចេញពីមណ្ឌលថែទាំ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា គឺជាអាជ្ញាធរមានសមត្ថកិច្ចទទួលខុសត្រូវក្នុងការរៀបចំធ្វើសមាហរណកម្មនេះ។ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ចាត់ថា ការទទួលបានជោគជ័យនៃសមាហរណកម្ម និងការបិទករណី ប្រសិនបើ៖

- ទំនាក់ទំនងរវាងគ្រួសារ និងបុគ្គលដែលបានធ្វើសមាហរណកម្មនោះ មានស្ថេរភាព និងមាននិរន្តរភាព។
- ស្ថានភាពសេដ្ឋកិច្ចនៃគ្រួសារ មានស្ថេរភាព ហើយពួកគេអាចរស់បានដោយខ្លួនឯង។
- អ្នកដែលបានធ្វើសមាហរណកម្ម អាចចូលរួមនៅក្នុងសកម្មភាពជាធម្មតា ជាប្រចាំថ្ងៃ ដូចជា ទៅសាលារៀន រកប្រាក់ចំណូល (នៅខាងក្នុង ឬខាងក្រៅផ្ទះ) ទទួលការបណ្តុះបណ្តាលវិជ្ជាជីវៈ។ល។
- មានភស្តុតាងគ្រប់គ្រាន់ ដែលបង្ហាញថា អ្នកដែលបានធ្វើសមាហរណកម្ម មានស្ថេរភាពផ្នែកសេដ្ឋកិច្ច ផ្នែកសង្គម និងផ្លូវចិត្ត។

**អគារក្រសួងកិច្ចការនារី**
ផ្លូវទ្រង់មាន់ ភូមិដំណាក់ធំ ៣
សង្កាត់ ស្ទឹងមានជ័យ ភ្នំពេញ
ប្រអប់សំបុត្រ ១១៥៨
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ហ្វាក់ : (+៨៥៥) ២៣ ៨៨០ ៧៣៧
អ៊ីម៉ែល : mwa@online.com.kh
វេបសាយ : www.mowa.gov.kh